គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់
និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)



កិច្ចពិភាក្សា និងអនុសាសន៍ស្តីពី

# មណ្ឌលសុវត្ថិភាពនៅអាស៊ាន

ការឆ្លុះបញ្ចាំងពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ

# មាតិកា


០៣
ផ្នែកទី ១ ៖
សេចក្តីផ្តើម

០៥
ផ្នែកទី ២ ៖
គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ

០៩
ផ្នែកទី ៣ ៖
កិច្ចពិភាក្សា

៤២
ផ្នែកទី ៤ ៖
អនុសាសន៍

៤៧
ឯកសារយោង


រូបថតគម្រប ៖ តម្បាញនៅមជ្ឈមណ្ឌលគាំពារសុខុមាលភាពជនរងគ្រោះដោយអំពើជួញដូរមនុស្ស
ខេត្តប៉ាក់ធុមថានី ប្រទេសថៃ ( ក្រេឌីត ៖ Rawena Russell )


Australian Aid | ASEAN-Australia Counter Trafficking

**សេចក្តីបដិសេធ៖** ការបោះពុម្ពឯកសារនេះ ជាគម្រោងមួយរបស់គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ( ASEAN-ACT )។

ទស្សនៈដែលត្រូវបានបង្ហាញនៅក្នុងឯកសារនេះមិនតំណាងឱ្យគោលជំហរផ្លូវការ ឬទស្សនៈរបស់អាស៊ាន រដ្ឋសមាជិកអាស៊ាន និងមិនមែនជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលី ឬស្ថាប័នផ្សេងទៀតឡើយ។

# សេចក្ដីថ្លែងអំណរគុណ

គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) លើកកម្ពស់គោលនយោបាយ និងគំនិតផ្ដួចផ្ដើមកម្មវិធីប្រកបដោយលទ្ធផល ដែលរួមចំណែកយ៉ាងធំធេងដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (អនុសញ្ញា ACTIP) ជាពិសេសការឆ្លើយតបនឹងការការពារដែលជាតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ផ្អែកលើគំនិតផ្ដួចផ្ដើមកន្លងមករបស់ ACWC និងអនុវត្តតាម "គោលការណ៍ណែនាំអាស៊ានដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ សម្រាប់ធ្វើការជាមួយស្ត្រីដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស" និង "គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់សម្រាប់ការបំពេញតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស" ACWC បានដឹកនាំការអនុវត្ត "គម្រោងពហុឆ្នាំដើម្បីពង្រឹងសមត្ថភាពអ្នកឆ្លើយតបជួរមុខក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្ស ដោយប្រើប្រាស់អភិក្រមយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្ដោតលើជនរងគ្រោះ ("ហៅកាត់ថា គម្រោង")។ លទ្ធផលចុងក្រោយនៃគម្រោងនេះ រួមបញ្ចូលកិច្ចពិភាក្សាស៊ីជម្រៅលើការអនុវត្តផ្សេងៗដែលពាក់ព័ន្ធនឹងការផ្ដល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅអាស៊ាន រហូតឈានដល់ការចងក្រងឯកសារនេះ ដើម្បីធ្វើឱ្យការផ្ដល់មណ្ឌលសុវត្ថិភាពនៅក្នុងតំបន់មានភាពប្រសើរឡើង។

ACWC សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរដ្ឋសមាជិកអាស៊ានទាំងអស់ ដែលបានផ្ដល់ការគាំទ្រ ដូចជាការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅអំឡុងឆ្នាំ ២០២១-២០២២ ក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន ថៃ និងវៀតណាម ក៏ដូចជាការពិនិត្យមើលកិច្ចពិភាក្សាដែលមានការសម្របសម្រួល និងអនុសាសន៍ ដើម្បីធានាថា កិច្ចពិភាក្សា និងអនុសាសន៍ទាំងនោះផ្អែកតាមបរិបទអាស៊ាន។

ACWC សូមថ្លែងអំណរគុណជូនចំពោះលោកជំទាវ Sri Dantyi Anwar តំណាង ACWC ឥណ្ឌូនេស៊ីទទួលបន្ទុកសិទ្ធិស្ត្រី ដែលបានជោគជ័យក្នុងដឹកនាំការរៀបចំ និងបញ្ចប់ឯកសារ "កិច្ចពិភាក្សា និងអនុសាសន៍របស់ ACWC ស្ដីពីមណ្ឌលសុវត្ថិភាពនៅអាស៊ាន"។ ការវិភាគនេះបង្ហាញពីឱកាស យុទ្ធសាស្ត្រ និងមេរៀនសម្រាប់ការដោះស្រាយបញ្ហាប្រឈមស្មុគស្មាញនៅក្នុងមណ្ឌលសុវត្ថិភាព ដែលបញ្ហាទាំងនោះកាន់តែរីកធំ ឡើងដោយសារផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់អ្នកដែលត្រូវជួញដូរ ដែលកំពុងទទួលបានការទំនុកបម្រុងនៅក្នុងមណ្ឌលសុវត្ថិភាព ឬហេដ្ឋារចនាសម្ព័ន្ធស្រដៀងគ្នា។

ACWC សូមសម្ដែងការដឹងគុណចំពោះភាពជាដៃគូដ៏រឹងមាំជាមួយក្រុមការងារកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងអំពើជួញដូរមនុស្ស (កម្មវិធី ASEAN-ACT) ក្នុងកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នេះ ជាពិសេសការជួយជ្រោមជ្រែងរបស់លោកស្រី Chen Chen ជាទីប្រឹក្សាកម្មវិធី ASEAN-ACT ដែលបានជួយដល់ ACWC ក្នុងដំណើរការពិគ្រោះយោបល់ និងការរៀបចំអនុសាសន៍ចេញពីការវិភាគកិច្ចពិភាក្សារបស់រដ្ឋសមាជិកអាស៊ាន។ ACWC សង្ឃឹមថានឹងទទួលបានការគាំទ្រជាបន្តទៀតពីកម្មវិធី ASEAN-ACT និងរដ្ឋាភិបាលអូស្ត្រាលី ជាពិសេសរដ្ឋសមាជិកអាស៊ាន ដើម្បីអនុវត្តអនុសាសន៍នៅក្នុងមណ្ឌលសុវត្ថិភាពសម្រាប់អ្នកដែលត្រូវបានគេជួញដូរ។

ចុងបញ្ចប់ ACWC សូមអរគុណចំពោះការគាំទ្រ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរបស់លេខាធិការដ្ឋានអាស៊ាន តាមរយៈផ្នែកកាត់បន្ថយភាពក្រីក្រ និងយេនឌ័រ នៅក្នុងដំណើរការរៀបចំ និងបញ្ចប់ឯកសារនេះ។

# ផ្នែកទី ១ ៖
# សេចក្តីផ្តើម

គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) តែងបានផ្តល់ការគាំទ្រជាបន្តបន្ទាប់ និងយ៉ាងមុតមាំ ដល់ការបកស្រាយ និងការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (អនុសញ្ញា ACTIP) តាំងពីដំបូង។ ACWC បានបោះពុម្ពផ្សាយឯកសារជាច្រើនដើម្បីគាំទ្រដល់ការការពារជនរងគ្រោះ ដូចជា គោលការណ៍ណែនាំអាស៊ានដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ សម្រាប់ធ្វើការជាមួយស្ត្រីដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស[១] និងគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់សម្រាប់ការបំពេញតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។[២]

ឯកសាររបស់ ACWC ស្តីពីកិច្ចពិភាក្សា និងអនុសាសន៍ស្តីពីមណ្ឌលសុវត្ថិភាពក្នុងតំបន់អាស៊ាន ត្រូវបានរៀបរៀងឡើងដើម្បីពិភាក្សាពីឱកាស យុទ្ធសាស្ត្រ និងមេរៀនក្នុងការលុបបំបាត់មណ្ឌលសុវត្ថិភាពបិទជិត និងការកែលម្អស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងពេលផ្តល់មណ្ឌលសុវត្ថិភាព។ ឯកសារនេះផ្អែកតាមកម្រងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដែលបានធ្វើឡើងក្នុងប្រទេសចំនួន ៦ នៅអាស៊ីអាគ្នេយ៍ រួមមានកម្ពុជា ឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន ថៃ និងវៀតណាម ចាប់ពីខែ ធ្នូ ឆ្នាំ ២០២១ ដល់ខែ មីនា ឆ្នាំ ២០២២។ សិក្ខាសាលាទាំងនេះចូលរួមដោយអ្នកអនុវត្តន៍ដែលមកពីស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល។ ឯកសារនេះផ្អែកលើការវិភាគ និងអនុសាសន៍ក្នុងការសិក្សាស្តីពីមណ្ឌលសុវត្ថិភាព ដែលរៀបចំឡើងដោយកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាស៊ាន-អូស្ត្រាលី (កម្មវិធី ASEAN-ACT) ក្នុងឆ្នាំ ២០១៨។

របាយការណ៍ឆ្នាំ ២០១៨ របស់កម្មវិធី ASEAN-ACT ដែលមានចំណងជើងថា "សេរីភាពបំលាស់ទីសម្រាប់អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ៖ ការវិភាគច្បាប់ គោលនយោបាយ និងការអនុវត្តក្នុងតំបន់អាស៊ាន" គឺជាការសិក្សាស្រាវជ្រាវដែលផ្តោតលើប្រទេស ៣ នៅអាស៊ាន រួមមាន ម៉ាឡេស៊ី ហ្វីលីពីន និងថៃ[៣]។ ជាពិសេស របាយការណ៍នេះពិនិត្យមើលស្ថានភាពនៃមណ្ឌលសុវត្ថិភាពបិទជិតដែលរឹតត្បិតសេរីភាពបំលាស់ទីរបស់បុគ្គលស្នាក់នៅក្នុងមណ្ឌល ទាំងក្នុងប្រទេសគោលដៅ និងប្រទេសបញ្ជូន។ របាយការណ៍នេះរកឃើញថាស្ថានភាពរបស់មណ្ឌលសុវត្ថិភាពបិទជិត គឺប្រហាក់ប្រហែលគ្នានឹងស្ថានភាពជាក់ស្តែងក្នុងមន្ទីរឃុំឃាំង ដោយសារការរៀបចំហេដ្ឋារចនាសម្ព័ន្ធ (ឧ. ការគ្រាប់តាមពន្ធនាគារ ឬគុក) ឬការរឹតត្បិតការបំលាស់ទីរបស់បុគ្គលស្នាក់នៅក្នុងមណ្ឌល សម្រាប់ជាលក្ខខណ្ឌមួយនៃការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។ មណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) ត្រូវបានរកឃើញថាមានភាពរឹតត្បិតដូចមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋដែរ។



[១] អាស៊ាន (២០១៦)៖ គោលការណែនាំស្តីពីការយកចិត្តទុកដាក់ចំពោះយេនឌ័រ សម្រាប់ធ្វើការជាមួយស្ត្រីរងគ្រោះដោយការជួញដូរមនុស្ស។ ហ្សាការតា៖ លេខាធិការដ្ឋានអាស៊ាន។ (https://asean.org/asean2020/wp-content/uploads/2021/01/Gender-Sensitive-Guidelines-for-Handling-Women-Victims-of-Trafficking-in-Persons- 2016.pdf)

[២] Unavailable online

[៣] Marika McAdam (2018)៖ "សេរីភាពបំលាស់ទីសម្រាប់អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ ការវិភាគច្បាប់ គោលនយោបាយ និងការអនុវត្តក្នុងតំបន់អាស៊ាន"។ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។ (https://www.aseanact.org/wp-content/uploads/2021/04/Freedom-of-movement_with-disclaimer.pdf)

# ផ្នែកទី ២ ៖
# គោលនយោបាយ និងក្របខ័ណ្ឌ
# គតិយុត្តពាក់ព័ន្ធ

## ២.១ ច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹងការមិនឃុំឃាំងជនរងគ្រោះ

- សិទ្ធិសេរីភាពក្នុងការដើរហើរ (មាត្រា ១២ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[៤]
- សិទ្ធិទទួលបានសេរីភាពផ្ទាល់ខ្លួន (មាត្រា ៩(១) នៃ ICCPR)
- សិទ្ធិមានការងារធ្វើ (មាត្រា ៦(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)[៥]
- ការហាមឃាត់ការឃុំឃាំងកុមារ ក្រោមអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)[៦] និងពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ[៧]
- សេរីភាពក្នុងការជ្រើសរើសកន្លែងស្នាក់នៅ និងលំនៅដ្ឋានរបស់ពួកគេ (មាត្រា ១៥) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)[៨]
- សិទ្ធិរបស់ជនពិការក្នុងការទទួលបានសេរីភាពដើរហើរ (មាត្រា ១៨) នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)។[៩]

គោលការណ៍ និងគោលការណ៍ណែនាំជាអនុសាសន៍ឆ្នាំ ២០០២ ស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ចែងថា "មិនត្រូវឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោសជនរងគ្រោះដោយអំពើជួញដូរមនុស្ស"។[១០] អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើជួញដូរមនុស្ស បានកត់សម្គាល់ថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានឃុំឃាំងក្នុងមណ្ឌលសុវត្ថិភាពបិទជិត នៅតាមបណ្តាប្រទេសជាច្រើន និងលើកឡើងថា ខណៈដែលនេះគឺសម្រាប់ជាផ្នែកមួយនៃកញ្ចប់ជំនួយ មិនមានជនរងគ្រោះនៃបទល្មើសណាម្នាក់ ត្រូវទទួលរងវិធានការរឹតត្បិតដូច្នេះ ដើម្បីជាការការពារខ្លួនពួកគេឡើយ[១១]។

[៤] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបើកឱ្យចុះហត្ថលេខានៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, ៩៩៩ U.N.T.S 3 ចូលជាធរមាននៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៦ ( https://www.ohchr.org/en/instruments-mechanisms/instruments/international-covenant-civil-and-political-rights )

[៥] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ បើកឱ្យចុះហត្ថលេខា ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, ៩៩៣ U.N.T.S.3 ចូលជាធរមាននៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៦ ( https://www.ohchr.org/en/instruments-mechanisms/instruments/international-covenant-economic-social-and-cultural-rights )

[៦] អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានអនុម័តដោយ GA Res 44/25 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ចូលជាធរមាននៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩០ ( https://www.ohchr.org/en/instruments-mechanisms/instruments/convention-rights-child )

[៧] ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ត្រូវបានអនុម័តដោយ GA Res 54/263 ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០០ ចូលជាធរមាននៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២។

[៨] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុម័តដោយមហាសន្និបាតនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៩ ចូលជាធរមាននៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៨១ ( https://www.ohchr.org/en/instruments-mechanisms/instruments/convention-elimination-all-forms-discrimination-against-women )

[៩] អនុសញ្ញាស្តីពីសិទ្ធិជនពិការ ត្រូវបានអនុម័តដោយ GA Res 61/106 ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ ចូលជាធរមាននៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០០៨ ( https://www.ohchr.org/en/instruments-mechanisms/instruments/convention-rights-persons-disabilities )

[១០] សូមមើលគោលការណ៍ជាអនុសាសន៍លេខ ៧ នៃគោលការណ៍ និងគោលការណ៍ណែនាំជាអនុសាសន៍ស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស។ សេចក្តីបន្ថែម របាយការណ៍របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដាក់ជូនក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម UN Doc. E/2002/68/Add.1 ( ២០ ឧសភា ២០០២ )។

[១១] មតិទូទៅលេខ ៥ (២០២០) ស្តីពីសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ក្នុងការទទួលបានសេរីភាព និងការរួចផុតពីការឃុំឃាំងតាមអំពើចិត្ត របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ ( https://www.ohchr.org/en/documents/general-comments-and-recommendations/comments-special-rapporteur-draft-general-comment-no )



# ២.២ ច្បាប់ និងក្របខ័ណ្ឌតំបន់ដែលពាក់ព័ន្ធការមិនឃុំឃាំងជនរងគ្រោះ

មាត្រា ១៤(៨) នៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ចែងថា "ភាគីនីមួយៗមិនត្រូវឃុំទុកមិនសមហេតុផលនូវជនណាម្នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយអាជ្ញាធរ មានសមត្ថកិច្ចរបស់ខ្លួនថាជាជនរងគ្រោះដោយសារការជួញដូរ នៅក្នុងការឃុំឃាំង ឬក្នុងពន្ធនាគារឡើយ នៅមុន នៅក្នុងអំឡុងពេល ឬក្រោយពេលមាននីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលសម្រាប់អំពើជួញដូរមនុស្ស"។[១២]

មាត្រា ១៦ នៃអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សក្នុងមហាអនុតំបន់ទន្លេមេគង្គ (COMMIT MOU) តម្រូវឱ្យរដ្ឋសមាជិកទាំង ៦ "ធានាថា អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនត្រូវបានឃុំឃាំងដោយអាជ្ញាធរអនុវត្តន៍ច្បាប់"។[១៣]

## ២.៣ ច្បាប់ជាតិដែលពាក់ព័ន្ធនឹងការមិនឃុំឃាំងជនរងគ្រោះ

រដ្ឋសមាជិកអាស៊ានស្ទើរតែទាំងអស់សុទ្ធតែមានច្បាប់ជាតិ ឬគោលការណ៍ណែនាំដែលចែងពីមណ្ឌលសុវត្ថិភាព និង/ឬកន្លែងស្នាក់នៅបណ្ដោះអាសន្នសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

មាត្រា ៣៣ នៃច្បាប់វៀតណាមស្ដីពីការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស ចែងថា ជនរងគ្រោះអាចទទួលបានមណ្ឌលសុវត្ថិភាពបណ្ដោះអាសន្ន។ ក្រៅពីនេះ ក្រឹត្យវៀតណាមលេខ ៦២/២០១២/ND-CP ដែលចែងពីមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការការពារសុវត្ថិភាពរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ លើកឡើងពីការផ្ដល់មណ្ឌលសុវត្ថិភាពបណ្ដោះអាសន្ន ក្នុងមាត្រា ៧។

មាត្រា ១៩ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សរបស់សិង្ហបុរី រៀបរាប់ពីការផ្ដល់មណ្ឌលសុវត្ថិភាពបណ្ដោះអាសន្ន និងសេវាពិគ្រោះយោបល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

គោលការណ៍ណែនាំប្រតិបត្តិការក្រុមពហុវិស័យរបស់ប្រទេសថៃ សម្រាប់ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចែងពីការផ្ទេរអ្នកដែលអាចជាជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅមណ្ឌលសុវត្ថិភាព។ យោងតាមមាត្រា ៣៣ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជននៃព្រះរាជាណាចក្រថៃ ត្រូវផ្ដល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមទាំងមណ្ឌលសុវត្ថិភាព។

ជំពូក ២៣ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្សរបស់ហ្វីលីពីន រៀបរាប់ពីសេវាជាកាតព្វកិច្ចសម្រាប់អ្នកដែលត្រូវបានជួញដូរ ដែលរួមបញ្ចូលមណ្ឌលសុវត្ថិភាពជាការសង្គ្រោះបន្ទាន់ ឬលំនៅដ្ឋានសមស្រប។

មាត្រា ៤២-៤៧ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងច្បាប់ប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ របស់ម៉ាឡេស៊ី លើកឡើងពីការផ្ដល់មណ្ឌលសម្រាប់អ្នកដែលត្រូវបានជួញដូរ។

មាត្រា ៤៤-៥០ នៃច្បាប់ស្ដីពីការប្រឆាំងអំពើជួញដូរមនុស្សរបស់ឡាវ ចែងពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានជំនួយ រួមទាំងមណ្ឌលសុវត្ថិភាពបណ្ដោះអាសន្ន។ ក្រៅពីនេះ មាត្រា ៤០ នៃច្បាប់ឡាវស្ដីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ ចែងពីវិធានការបន្ទាន់សម្រាប់ការការពារ រួមទាំងការត្រឡប់ទៅរស់នៅជាមួយឪពុកម្ដាយ ឬមណ្ឌលសុវត្ថិភាព ប្រសិនបើមិនអាចវិលត្រឡប់ទៅវិញបាន។

មាត្រា ៤៦ និងមាត្រា ៥២ នៃច្បាប់លេខ ២១ របស់ឥណ្ឌូនេស៊ី ស្ដីពីការលុបបំបាត់ច្បាប់ព្រហ្មទណ្ឌស្ដីពីអំពើជួញដូរមនុស្ស តម្រូវឱ្យរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ខេត្តសាងសង់មណ្ឌលសុវត្ថិភាព និងមជ្ឈមណ្ឌលព្យាបាលរបួស ដើម្បីផ្ដល់ការស្ដារលទ្ធភាពវេជ្ជសាស្ត្រ និងសង្គម ជំនួយដល់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មក្នុងសង្គម។ មាត្រា ២២៣ នៃបទបញ្ញត្តិរដ្ឋាភិបាលស្ដីពីការអនុវត្តច្បាប់លេខ ៦/២០១១ ស្ដីពីអន្តោប្រវេសន៍ (លេខ ៣១/២០១៣) ចែងពីកន្លែងស្នាក់នៅសម្រាប់ជនបរទេសដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងប្រទេសឥណ្ឌូនេស៊ី។

# ផ្នែកទី ៣ ៖
# កិច្ចពិភាក្សា

## ៣.១ ពាក្យបច្ចេកទេស និងការយល់ដឹងពីមណ្ឌលសុវត្ថិភាពមិនជិត

នៅតាមបណ្តាប្រទេសជាសមាជិកអាស៊ានដែលត្រូវបានប្រឹក្សាយោបល់សម្រាប់ឯកសារនេះ មានការប្រើប្រាស់ពាក្យពេចន៍ជាច្រើនពាក់ព័ន្ធនឹងការផ្តល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដូចជា "កន្លែងស្នាក់នៅបណ្តោះអាសន្ន" "មណ្ឌលការពារ" "ការការពារឃុំគ្រង" "ផ្ទះសុវត្ថិភាព" "មណ្ឌលសុខុមាលភាព" ។ល។ ការប្រើពាក្យ "មណ្ឌលការពារ" និង "ការការពារឃុំគ្រង" គូសបញ្ជាក់ពីការយល់ឃើញយ៉ាងទូលំទូលាយថា មណ្ឌលសុវត្ថិភាពសម្រាប់ជនរងគ្រោះមានគោលបំណងចម្បងក្នុងការផ្តល់ការការពារ ជាពិសេសការការពារពីអ្នកជួញដូរមនុស្ស និងការគំរាមកំហែងផ្សេងទៀត ហើយនេះជាអ្វីដែលត្រូវបានគូសបញ្ជាក់ក្នុងរបាយការណ៍ ឆ្នាំ ២០១៨ របស់កម្មវិធី ASEAN-ACT។

មានការឯកភាពទូទៅថា ជនរងគ្រោះដោយអំពើជួញដូរមនុស្សមិនគួរត្រូវបានឃុំឃាំងនោះទេ ដោយអ្នកចូលរួមក្នុងសិក្ខាសាលារំលឹកពីបទបញ្ញត្តិក្នុងមាត្រា ១៤ នៃអនុសញ្ញា ACTIP ដែលអំពាវនាវមិនឱ្យរដ្ឋដាក់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងការឃុំឃាំង ឬក្នុងពន្ធនាគារដោយមិនសមហេតុផលឬដាក់ទណ្ឌកម្មពួកគេដោយសារសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបនោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស[១៤]។ ការឃុំឃាំងពាក់ព័ន្ធនឹងការជាប់ឃុំក្នុងកន្លែងឃុំខ្លួនជនអន្តោប្រវេសន៍ គុក ពន្ធនាគារ។ល។ ដែលជនរងគ្រោះត្រូវបានចាត់ទុកជាជនល្មើស ឬឧក្រិដ្ឋជន។ ដូច្នេះ ភាគីពាក់ព័ន្ធភាគច្រើន (ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល) សង្កេតឃើញថា ទាំងទស្សនទាន និងការអនុវត្ត "ការឃុំឃាំងក្នុង



មណ្ឌលសុវត្ថិភាព” ដែលពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺលែងមានទៀតហើយដោយសារការអនុលោមតាមកាន់តែប្រសើរតាមច្បាប់ក្នុងស្រុក និងការសង្កត់ធ្ងន់កាន់តែខ្លាំងពីសិទ្ធិមនុស្សរបស់ជនរងគ្រោះ។

ទន្ទឹមនឹងនេះ ក៏មានការភាន់ច្រលំពីពាក្យបច្ចេកទេសផ្សេងៗដែលត្រូវបានប្រើប្រាស់ អាស្រ័យលើភាគីពាក់ព័ន្ធដែលប្រើប្រាស់ពាក្យទាំងនោះ។ មណ្ឌលសុវត្ថិភាពត្រូវបានពិពណ៌នាថា "បើកចំហរ" "ពាក់កណ្តាលបិទជិត" និង "បិទជិត" ដោយមិនមានការយល់ដឹងជារួមនៅថ្នាក់ជាតិអំពីអត្ថន័យពិតប្រាកដនៃពាក្យទាំងនេះ នៅក្នុងការអនុវត្ត។

លក្ខណៈនៃការស្នាក់នៅរយៈពេលខ្លីក្នុងមណ្ឌលសុវត្ថិភាពភាគច្រើន ត្រូវបានលើកឡើងជាទឡ្ហីករណ៍ប្រឆាំងនឹងគោលគំនិតនៃមណ្ឌលសុវត្ថិភាពបិទជិត។ ក្នុងប្រទេសហ្វីលីពីន ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានដាក់ឱ្យស្នាក់នៅក្នុងមណ្ឌលថែទាំជាបណ្តោះអាសន្ន (ក្រោមកម្មវិធីស្តារឡើងវិញ និងសមាហរណកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស) ដែលបុគ្គលិកសង្គមកិច្ចធ្វើការជាមួយមន្ត្រីសុខុមាលភាព និងអភិវឌ្ឍន៍សង្គមក្នុងមូលដ្ឋាន ដើម្បីជូនដំណឹងដល់គ្រួសាររបស់ពួកគេ និងរៀបចំការវិលត្រឡប់ទៅផ្ទះវិញឱ្យបានឆាប់រហ័ស។ ចំណុចសំខាន់គឺការជួយឱ្យជនរងគ្រោះអាចជួបជុំគ្រួសារដោយជោគជ័យ។ នៅវៀតណាម ជាទូទៅជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពដែលគេហៅថាផ្ទះសន្តិភាពដែលគ្រប់គ្រងដោយសហជីពស្ត្រីវៀតណាមរយៈពេល ៣-៦ ខែ និង Nhan Ai (ផ្ទះមេត្តា) ដែលគាំទ្រដោយ Pacific Links ក្នុងរយៈពេលរហូតដល់ ៤ ឆ្នាំ។ ផ្ទះសន្តិភាពជាកន្លែងដែលផ្តល់សេវាបណ្តោះអាសន្ន ដូចជា កន្លែងស្នាក់នៅសុវត្ថិភាព ការប្រឹក្សាចិត្តសាស្ត្រ ជំនួយផ្នែកច្បាប់ និងអាហារ។ ភាគីពាក់ព័ន្ធម្នាក់ដែលជាជនជាតិថៃ ទទួលស្គាល់ថា ជនរងគ្រោះភាគច្រើននៅក្នុងប្រទេសថៃ ត្រូវបានដាក់ឱ្យស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពបិទជិត និងជាទូទៅ គឺមិនមានបញ្ហាចោទនោះទេ ប្រសិនបើជាការស្នាក់នៅរយៈពេលខ្លី។ ទោះជាយ៉ាងណា ភាពអូសបន្លាយនៃបណ្តឹងតវ៉ាធ្វើឱ្យជនរងគ្រោះជាច្រើនត្រូវបានគេដាក់ក្រោមការឃុំគ្រង នៅក្នុងមណ្ឌលសុវត្ថិភាពរយៈពេលយូរ។

ការទទួលបានការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយពីជនរងគ្រោះ មុននឹងចូលទៅក្នុង មណ្ឌលសុវត្ថិភាព ជាវិធីមួយសម្រាប់សម្រាលផលប៉ះពាល់នៃការរឹតត្បិតសេរីភាពដើរហើរ។ ក្នុងការអនុវត្តការទទួលបានការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ហាក់ជាបទដ្ឋានមួយនៅតាមប្រទេសសមាជិកអាស៊ានជាច្រើន ជាទីដែលជនរងគ្រោះទទួលបានព័ត៌មានស្តីពីស្ថានភាពនៃការស្នាក់នៅ វិធានស្តីពីការប្រើប្រាស់ទូរស័ព្ទចល័ត ពេល និងស្ថានភាពដែលពួកគេអាចចាកចេញពីបរិវេណមណ្ឌលបាន។ល។ ប៉ុន្តែនីតិវិធីទូទៅនៃការទទួលបានការយល់ព្រមពីជនរងគ្រោះ ធ្វើឱ្យស្រពិចស្រពិលដល់កិច្ចពិភាក្សាស៊ីជម្រៅស្តីពីថាតើជនរងគ្រោះមួយចំនួនក្នុងចំណោមនេះមានជម្រើសពិតប្រាកដ ឬទេ។ នេះជាការពិតសម្រាប់ជនបរទេសដែលមិនមានកន្លែងត្រូវទៅ និងអ្នកដែលមិនមានជម្រើសអ្វីក្រៅពីការជាប់ឃុំក្នុងមន្ទីរឃុំឃាំងជនអន្តោប្រវេសន៍ ឬពន្ធនាគារ។



*ប្រសិនបើពិតជាមានជម្រើសមែន អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពប្រហែលជាមិនពន្យល់ដល់បុគ្គលស្នាក់នៅក្នុងមណ្ឌលថា ពួកគេអាចចាកចេញបាននោះទេ។ ដោយសារការប៉ះទង្គិចផ្លូវចិត្ត និងកង្វះស្វ័យភាពដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជនរងគ្រោះច្រើនតែស្ទាក់ស្ទើរមិនហ៊ានប្រឈមនឹងផលវិបាកអវិជ្ជមាន តាមរយៈការបញ្ចេញមតិ។*

*សម្រាប់ជនរងគ្រោះដែលជាជនបរទេស ភាពមិនប្រក្រតីនៃស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ អាចមានន័យថា ការដោះលែងភ្លាម គឺមិនអាចធ្វើទៅបានឡើយ ទោះបីជាមានការកំណត់ពីសិទ្ធិចាកចេញ នៅក្នុងទ្រឹស្តីក៏ដោយ។*

*៤. សំណើសុំចាកចេញពីមណ្ឌលសុវត្ថិភាពដ៏ធំមួយដែលគ្រប់គ្រងដោយរដ្ឋាភិបាលថៃ មិនត្រូវបានអនុញ្ញាតនោះទេ រហូតទាល់តែមានការចេញឯកសារចាំបាច់ផ្សេងៗ។ នេះជាដំណើរការមួយដែលអាចមានរយៈពេលជាច្រើនខែ ឬជាច្រើនឆ្នាំ។*[១៥]

ក្រៅពីនេះ មានការគូសបញ្ជាក់ពីការយល់ព្រមនៅពេលចូលស្នាក់នៅដំបូង ដោយមានការលើកឡើងតិចតួចស្ដីពីថាតើតែងតែមានការស្វះស្វែងរកការយល់ព្រមចូលស្នាក់ ឬទេ។ ខណៈដែលអ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពនិយាយថា ជនរងគ្រោះអាចចាកចេញបានគ្រប់ពេល ហើយជនរងគ្រោះមួយចំនួនពិតជាអាចធ្វើបានមែន មានឧបសគ្គជាក់ស្ដែងជាច្រើនដែលត្រូវដោះស្រាយ។

ស្រដៀងគ្នានឹងលទ្ធផលរកឃើញពីរបាយការណ៍ឆ្នាំ ២០១៨ របស់កម្មវិធី ASEAN-ACT ដំណើរកំសាន្តដែលមានអ្នកអមដំណើរ និងសកម្មភាពនៅក្រៅមណ្ឌលសុវត្ថិភាព (ដូចជា ទៅឆ្នេរសមុទ្រ ទៅពេងកុន ទៅបោះប៉ូល ឬដើរផ្សារ) និងលទ្ធភាពទទួលបានការងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវបានដកស្រង់ជាឧទាហរណ៍នៃសេរីភាពដើរហើរក្នុងអំឡុងពេលនៃការពិគ្រោះយោបល់ថ្នាក់ជាតិ ឆ្នាំ ២០២២។ ភាគីពាក់ព័ន្ធក្នុងប្រទេសឡាវ អះអាងថា ឡាវមិនមានមណ្ឌលសុវត្ថិភាពដែលមានលក្ខណៈដូចមន្ទីរឃុំឃាំងនោះទេ ប៉ុន្តែមានមណ្ឌលសុវត្ថិភាព "ពាក់កណ្ដាលបិទជិត"។ អង្គការមិនមែនរដ្ឋាភិបាលមួយក្នុងប្រទេសឡាវ លើកឡើងថា អ្នករស់នៅក្នុងផ្ទះសុវត្ថិភាពមានសិទ្ធិពេញលេញ និងអាចធ្វើឱ្យបរិយាកាសក្នុងផ្ទះសុវត្ថិភាពដូចគ្នានឹងបរិយាកាសនៅផ្ទះ។ ផ្ទះសុវត្ថិភាពផ្ដល់សកម្មភាព និងការគាំទ្រជាច្រើនដល់បុគ្គលស្នាក់នៅក្នុងមណ្ឌល ហើយបុគ្គលស្នាក់នៅក្នុងមណ្ឌលអាចទាក់ទង និងជួបជាមួយក្រុមគ្រួសាររបស់ពួកគេបាន។ ក្នុងការឆ្លុះទស្សនៈខាងលើ សហជីពស្ត្រីឡាវដែលទទួលខុសត្រូវលើការផ្ដល់មណ្ឌលសុវត្ថិភាព និងការស្ដារលទ្ធភាពរាងកាយរបស់ស្ត្រីដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងប្រទេសឡាវ បានលើកឡើងថា៖

*យើងមានសកម្មភាពមួយចំនួនដើម្បីបន្ធូរភាពតានតឹង និងភាពតប់ប្រមល់ (របស់បុគ្គលស្នាក់នៅក្នុងមណ្ឌល) និងព្យាបាលពួកគេតាមរយៈពិធីជាលក្ខណៈវប្បធម៌។ ក្រៅពីនេះ យើងនាំពួកគេទៅក្រៅដើម្បីស្វែងយល់បន្ថែម ដូចជា ទៅផ្សារ ទស្សនាទីក្រុង ប៉ុន្តែ (បុគ្គលស្នាក់នៅក្នុងមណ្ឌល) នឹងអមដំណើរដោយបុគ្គលិករបស់យើង ព្រោះពួកគេនៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់យើង ហើយយើងទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់ពួកគេ។*

មានការលើកឡើងពីការយល់ឃើញចំពោះ "សេរីភាពបំលាស់ទី" ចេញពីទស្សនៈរបស់ជនរងគ្រោះ ប៉ុន្តែមិនមានការពិភាក្សាឱ្យបានស៊ីជម្រៅនោះទេ។ ការណ៍នេះបង្ហាញថា ប្រហែលជាមិនមានការពិចារណាគ្រប់គ្រាន់ពីទស្សនៈរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះទេ ហើយក៏មិនមានការបញ្ចូលទស្សនៈទាំងនោះទៅក្នុងការរៀបចំកម្មវិធីមណ្ឌលសុវត្ថិភាពនៅអាស៊ានដែរ។ ទោះជាយ៉ាងណា ការអនុវត្តល្អជាអន្តរជាតិបានបង្ហាញថា ការអនុវត្តកម្មវិធី និងការផ្ដល់សេវាដែលមានគុណភាពខ្ពស់អាចផ្អែកតាមចំណេះដឹង និងបទពិសោធន៍របស់អ្នកដែលចូលរួមក្នុងកម្មវិធីទាំងនេះ ពោលគឺអ្នកដែលត្រូវបានជួញដូរ។ អ្នកចូលរួមក្នុងសិក្ខាសាលាម្នាក់ព្រមានថា ការមិនប្រើប្រាស់ពាក្យ "ការឃុំឃាំងក្នុង មណ្ឌលសុវត្ថិភាព" មិនមែនមានន័យថា មិនមានការអនុវត្តដូច្នេះនោះទេ។ ប្រសិនបើជនរងគ្រោះយល់ថា ពួកគេត្រូវបាន "ឃុំឃាំង" ឬប្រសិនបើពួកគេយល់ថា សេរីភាពរបស់ពួកគេត្រូវបានដកហូត មានន័យថា តាមពិត និងតាមការគិតរបស់ជនរងគ្រោះ គឺមានការឃុំឃាំងហើយ ដោយមិនគិតថាតើអ្នកផ្ដល់សេវាហៅមណ្ឌលនោះ ជាមណ្ឌលសុវត្ថិភាពអ្វីនោះទេ។



កម្ពុជាបានតាក់តែងគោលនយោបាយមួយ ស្តីពីការការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ប្រកាសលេខ ៨៥២) ដូចជា ស្តង់ដារអប្បបរមាសម្រាប់ការការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ប្រកាសលេខ ៨៥៧) (២០០៩) ដែលលើកឡើងពីការផ្តល់សេវា និងការថែទាំដល់ជនរងគ្រោះដែលស្ថិតក្នុងមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋ និងមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ មាត្រា ៤៣ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្សរបស់ប្រ៊ុយណេចែងពីការផ្តល់មណ្ឌលសុវត្ថិភាពឬកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់អ្នកដែលត្រូវបានជួញដូរ។

[១២] សូមមើលមាត្រា ១៤(៨) នៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលត្រូវបានអនុម័តដោយអាស៊ាននៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៥ (https://asean.org/asean-convention-against-trafficking-in-persons-especially-women-and-children/)

[១៣] អនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៤។ រដ្ឋសមាជិក COMMIT រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

[១៤] សូមមើលផងដែរ Marika McAdam (២០២២) ការអនុវត្តគោលការណ៍ស្តីពីការមិនដាក់ទណ្ឌកម្មចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងរដ្ឋសមាជិកអាស៊ាន។ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។ (https://www.aseanact.org/wp-content/uploads/2022/04/Non- Punishment_print_smallsize.pdf)

[១៥] Anne Gallagher and Elaine Pearson (2008), "Detention of Trafficked Persons in Shelters: A legal and policy analysis"; Anne Gallagher and Elaine Pearson, 'The High Cost of Freedom: A Legal and Policy Analysis of Shelter Detention for Victims of Trafficking', Human Rights Quarterly 32 (2010) 73-114.

[១៦] Surtees R (2013). After Trafficking: Experiences and Challenges in the (Re) Integration of Trafficked Persons in the Greater Mekong Sub-Region. Bangkok, Thailand: UNIAP/ NEXUS Institute.

[១៧] សូមមើល http://kredtrakarnhome.com/Home-USLeng.html

[១៨] ម៉ូដែលមណ្ឌលសុវត្ថិភាពរីករាយ ជាគំនិតផ្តួចផ្តើមថ្មីមួយរបស់ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជន នៃព្រះរាជាណាចក្រថៃ ដើម្បីផ្តល់ទាំងមណ្ឌលសុវត្ថិភាពបណ្តោះអាសន្ន និងមណ្ឌលសុវត្ថិភាពរយៈពេលវែងដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលជាជនជាតិថៃ ឬមិនមែនជនជាតិថៃ។ ម៉ូដែលនេះផ្តោតសំខាន់លើការកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ សូមមើល https://www.aseanact.org/story/happy-shelters/។

[១៩] សូមមើល Marika McAdam (២០១៨) សេរីភាពបំលាស់ទីសម្រាប់អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ ការវិភាគច្បាប់ គោលនយោបាយ និងការអនុវត្តក្នុងតំបន់អាស៊ាន។ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។ Anne Gallagher and Marika McAdam (ND). 'Information Note on Freedom of movement for victims of trafficking'. ASEAN-Australia Counter Trafficking.

## ៣.២ ការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ និងភាគីខាងក្រៅ

ការដកហូតលទ្ធភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងការទូរស័ព្ទទាក់ទងទៅក្រុមគ្រួសារ មិត្តភក្តិ ឬមេធាវីរបស់ពួកគេ គឺជាការរំលោភសិទ្ធិសេរីភាពរបស់ពួកគេ។ ការកាត់ផ្តាច់ជនរងគ្រោះពីមនុស្សនៅខាងក្រៅមណ្ឌលសុវត្ថិភាព (ទោះបីជាមានចេតនាល្អក៏ដោយ) អាចប្រៀបដូចជាការដាក់ទណ្ឌកម្ម និងការឃុំឃាំង។ ជាទូទៅ អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាព រឹតត្បិតជំនួបជាមួយគ្រួសារសាច់ញាតិនៅក្នុងមណ្ឌលសុវត្ថិភាព និងត្រួតពិនិត្យទំនាក់ទំនងរបស់បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។ ទោះជាយ៉ាងណា ការស្រាវជ្រាវបង្ហាញថា ការមិនអនុញ្ញាតឱ្យទាក់ទងជាមួយសមាជិកគ្រួសារ អាចធ្វើឱ្យជនរងគ្រោះពិបាកចិត្ត ព្រោះពួកគេព្រួយបារម្ភពីសុខុមាលភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារ នៅពេលស្នាក់នៅក្នុងមណ្ឌល[១៦]។ ការបំបែកពីគ្រួសារអាចធ្វើឱ្យជនរងគ្រោះមានអារម្មណ៍ថប់បារម្ភ ទាល់ច្រក និងទុក្ខសោក។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ បានរំលេចចម្ងល់ជាច្រើនពាក់ព័ន្ធនឹងការកាន់កាប់ និងការប្រើប្រាស់ទូរស័ព្ទចល័តដោយបុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព និងសមត្ថភាពរបស់ពួកគេក្នុងការប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសារ។ ក្នុងចំណោមប្រទេសសមាជិកអាស៊ានដែលត្រូវបានអង្កេតសម្រាប់ឯកសារនេះ មិនមានប្រទេសណាមួយមានកម្រងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីចំណុចនេះទេ ហើយវិធានប្រែប្រួលទៅតាម មណ្ឌលសុវត្ថិភាពនីមួយៗនៅក្នុងប្រទេស។

ក្នុងប្រទេសថៃ មណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋ បានបន្ធូរបន្ថយវិធានរបស់ខ្លួនស្តីពីការប្រើប្រាស់ទូរស័ព្ទចល័ត ដោយអនុញ្ញាតឱ្យបុគ្គលស្នាក់នៅក្នុងមណ្ឌលប្រើប្រាស់ទូរស័ព្ទចល័តស្ទើរតែដោយសេរី ក្នុងម៉ោងធ្វើការ។ បុគ្គលស្នាក់នៅក្នុងមណ្ឌល អាចប្រើ Wi-Fi និងអ៊ីនធឺណិតក្នុងមណ្ឌលសុវត្ថិភាព ដើម្បីទទួលបានជំនាញការងារឬតាមដានព័ត៌មាននៅស្រុកកំណើតឬលំនៅដ្ឋានរបស់ពួកគេ។ ពីមុន ពួកគេត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទូរស័ព្ទចល័តត្រឹម ២ ថ្ងៃក្នុងមួយសប្តាហ៍ប៉ុណ្ណោះ។ មជ្ឈមណ្ឌលជួយស្ត្រីមានវិបត្តិមួយនៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលផ្តល់ការស្នាក់នៅរយៈពេល ១៤ ថ្ងៃដល់ស្ត្រី និងក្មេងស្រីក្រីក្រ លើកឡើងថា ក្នុងអំឡុងពេលនេះ បុគ្គលស្នាក់នៅក្នុងមណ្ឌលមិនត្រូវបានអនុញ្ញាតឱ្យមាន ឬប្រើប្រាស់ទូរស័ព្ទចល័តនោះទេ។ ក្នុងករណីមួយចំនួន ការរឹតត្បិតនេះគឺដោយសារតែទូរស័ព្ទចល័តត្រូវបានប្រើប្រាស់ដោយអ្នកជួញដូរមនុស្ស ឬជនរងគ្រោះផ្ទាល់ សម្រាប់ជាមធ្យោបាយប្រព្រឹត្តបទល្មើស ដូច្នេះ វាត្រូវបានដកហូតជាឯកសារកោសលវិច័យ។ ក្នុងករណីផ្សេងទៀត ជនរងគ្រោះព្រួយបារម្ភពីសារជាអក្សរនៅក្នុងទូរស័ព្ទចល័តរបស់ពួកគេ ពោលគឺសារដែលជនរងគ្រោះបានផ្តល់ "ការយល់ព្រម" ដល់ជនល្មើស។ ដូច្នេះ យោងតាមមជ្ឈមណ្ឌលនេះ ការដកហូតទូរស័ព្ទរបស់ជនរងគ្រោះ នឹងជួយការពារពួកគេមិនឱ្យព្រួយបារម្ភពេកអំពីស្ថានភាពផ្ទាល់ខ្លួន។

ភាគីពាក់ព័ន្ធនៅអាស៊ានយល់ស្របថា មានហេតុផលសន្តិសុខដែលចាំបាច់ត្រូវដកហូតទូរស័ព្ទចល័តរបស់ជនរងគ្រោះ ដែលហេតុផលចម្បងបង្អស់គឺសមត្ថភាពរបស់អ្នកជួញដូរមនុស្សក្នុងការកំណត់ទីតាំងរបស់ជនរងគ្រោះ។ ជនរងគ្រោះអាចចៀសមិនផុតពីការបង្ហាញទីតាំងមណ្ឌលសុវត្ថិភាពរបស់ពួកគេដល់អ្នកជួញដូរមនុស្ស ឬក៏អ្នកជួញដូរមនុស្សអាចកំណត់អត្តសញ្ញាណមណ្ឌលសុវត្ថិភាពដោយប្រើប្រាស់កម្មវិធីតាមដាន ដែលត្រូវបានតម្លើងជាស្រេចនៅក្នុងទូរស័ព្ទចល័តរបស់ជនរងគ្រោះ។ អ្នកគ្រប់គ្រងមណ្ឌល និងបុគ្គលិកសង្គមកិច្ចប្រយ័ត្នប្រយែងខ្លាចអ្នកជួញដូរមនុស្ស ឬក្រុមគ្រួសារទាក់ទងទៅជនរងគ្រោះ ជាពិសេសប្រសិនបើក្រុមគ្រួសាររបស់ជនរងគ្រោះឃុបឃិតក្នុងការរំលោភបំពាន និងកេងប្រវ័ញ្ចជនរងគ្រោះ។ ពួកគេបារម្ភថា ការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់ដំណើរការស្តារឡើងវិញរបស់ជនរងគ្រោះ ក៏ដូចជាឆន្ទៈរបស់ជនរងគ្រោះក្នុងការបន្តចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ អ្នកអនុវត្តន៍គូសបញ្ជាក់ពីការលំបាកក្នុងការរក្សាតុល្យភាពរវាងហានិភ័យសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ និងសិទ្ធិរបស់ជនរងគ្រោះក្នុងការប្រាស្រ័យទាក់ទងជាមួយគ្រួសារ និងមនុស្សជិតស្និទ្ធ។អង្គការមិនមែនរដ្ឋាភិបាលនៅឥណ្ឌូនេស៊ីលើកឡើងពីការកំណត់យកចំណុចនេះសម្រាប់ពន្យល់ពីវិធាននៃការប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងមណ្ឌលសុវត្ថិភាព និងហានិភ័យនៃការធ្វើដូច្នោះ។ ជនរងគ្រោះត្រូវផ្តល់ការយល់ព្រមឱ្យដកហូតទូរស័ព្ទចល័តរបស់ពួកគេ។ ប្រសិនបើចាំបាច់ បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពនឹងទទួលបានទូរស័ព្ទចល័តថ្មីដើម្បីកាត់បន្ថយហានិភ័យដែលអ្នកជួញដូរមនុស្សទាក់ទងទៅជនរងគ្រោះ។

ពាក់ព័ន្ធនឹងកុមារ គោលការណ៍តម្កល់ឧត្តមប្រយោជន៍រស់កុមារត្រូវបានលើកឡើងថាជាមគ្គុទេសក៍សម្រាប់ការប្រព្រឹត្តចំពោះជនរងគ្រោះជាកុមារនៅក្នុងមណ្ឌលសុវត្ថិភាព។ អ្នកផ្តល់សេវាគូសបញ្ជាក់ពីបញ្ហាប្រឈមក្នុងការអនុវត្តចំណុចនេះ។ ទីមួយ ពួកគេត្រូវវាយតម្លៃថាតើការជួបជុំជាមួយគ្រួសាររបស់ពួកគេ គឺជាជម្រើសល្អបំផុតសម្រាប់កុមារ ឬទេ។ នេះអាចជាដំណើរការស្មុគស្មាញមួយ ដែលអាស្រ័យលើកាលៈទេសៈរបស់កុមារ និងការមានជម្រើសសមស្របផ្សេងៗ។ ទីពីរ នីតិវិធីបែបការិយាធិបតេយ្យហួសកម្រិត និងកង្វះការសម្របសម្រួលរវាងអ្នកផ្តល់សេវា បានបង្កើតឱ្យមានភាពតានតឹងហួសហេតុ និងការភាន់ច្រលំដល់មនុស្សគ្រប់គ្នា។ អង្គការមិនមែនរដ្ឋាភិបាលមួយនៅឥណ្ឌូនេស៊ី បានចែករំលែកពីបទពិសោធន៍របស់កុមារម្នាក់ដែលត្រូវបានផ្ទេរពីមណ្ឌលសុវត្ថិភាពទៅផ្ទះការពារ និងមជ្ឈមណ្ឌលព្យាបាលរបួស (RPTC)។ គ្រួសាររបស់កុមារនោះត្រូវបានរារាំងមិនឱ្យទៅលេង ឬនិយាយជាមួយកុមារ។ អង្គការនោះមិនអាចធ្វើអ្វីបានទេ ព្រោះពួកគេមានកាតព្វកិច្ចតាមដានពិធីសារសុវត្ថិភាពដែលកំណត់ដោយ RPTC ដូច្នេះ ពួកគេត្រូវបានគ្រួសាររបស់កុមារស្តីបន្ទោសចំពោះការរារាំងមិនឱ្យប្រាស្រ័យទាក់ទងជាមួយកុមារនោះ។

តំណាងម្នាក់មកពីមជ្ឈមណ្ឌលការពារ និងអភិវឌ្ឍន៍មុខរបរKredtrakarn[១៧]ក្នុងប្រទេសថៃលើកឡើងថាជំងឺកូវីដ-១៩ បានផ្លាស់ប្តូរវិធានស្តីពីការប្រាស្រ័យទាក់ទង

របស់បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពជាមួយភាគីខាងក្រៅ។ កាលពីមុនវិបត្តិកូវីដ-១៩ ឪពុកម្តាយអាចទៅលេងកូនបាន ដូច្នេះ បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពមិនចាំបាច់មានទូរស័ព្ទចល័តនោះទេ។ ក្នុងករណីដែលឪពុកម្តាយរស់នៅឆ្ងាយពីមជ្ឈមណ្ឌល បុគ្គលិកនឹងរៀបចំថ្ងៃ និងពេលសម្រាប់ឱ្យកូនទូរស័ព្ទទៅឪពុកម្តាយ ដោយប្រើទូរស័ព្ទក្នុងមជ្ឈមណ្ឌល។ ជាមួយនឹងការបង្កើតម៉ូដែលមណ្ឌលសុវត្ថិភាពរីករាយ[១៨] មណ្ឌលអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធី LINE ដើម្បីទាក់ទងគ្នាជាវីដេអូ (video call) ពីចម្ងាយ ដែលអាចឱ្យបុគ្គលស្នាក់នៅក្នុងមណ្ឌលឃើញមុខក្រុមគ្រួសារ និងធ្វើឱ្យពួកគេមានអារម្មណ៍កាន់តែរីករាយ និងកាន់តែសហការ។ មណ្ឌលតម្រូវឱ្យមានវត្តមានបុគ្គលិកម្នាក់ ប្រសិនបើអ្នកប្រើទូរស័ព្ទមានអាយុក្រោម ១៨ ឆ្នាំ ដើម្បីធានាថា បុគ្គលិកនោះអាចធ្វើអន្តរាគមន៍ និងទ្រទ្រង់សុខុមាលភាពរបស់កុមារបាន ប្រសិនបើឪពុក/ម្តាយនិយាយអ្វីមិនល្អទៅកាន់កុមារ។



## ៣.៣ សន្និទានភាពសម្រាប់ការរឹតត្បិតសេរីភាពដើរហើររបស់ជនរងគ្រោះ

របាយការណ៍ឆ្នាំ ២០១៨ របស់កម្មវិធី ASEAN-ACT រកឃើញថា ការរឹតត្បិតសេរីភាពដើរហើររបស់ជនរងគ្រោះ ច្រើនតែសំអាងលើទឡ្ហីករណ៍ធំៗ ៣ មានជាអាទិ៍ ការការពារ ជំនួយ និងការផ្តន្ទាទោស[១៩]។

ក្នុងចំណោមប្រទេសជាសមាជិកអាស៊ានដែលចូលរួមក្នុងសិក្ខាសាលានេះ ***ការការពារ*** នៅតែជាមូលហេតុចម្បងបំផុតនៃការរក្សាឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សស្ថិតនៅក្នុងមណ្ឌលសុវត្ថិភាពបិទជិត ឬពាក់កណ្តាលបិទជិត។ សន្និទានភាពនៃការការពារ កើតចេញពីការយល់ថា ជនរងគ្រោះត្រូវទទួលបានការការពារពីអ្នកជួញដូរមនុស្ស និងអ្នកដទៃទៀតដែលអាចពាក់ព័ន្ធក្នុងអំពើជួញដូរជនរងគ្រោះ ដូចជា មេខ្យល់ ឬសមាជិកគ្រួសារ។ សន្និទានភាពនេះផ្អែកលើការសន្មតថា ជនរងគ្រោះដែលអាចដើរហើរដោយសេរី នឹងរងរបួស ត្រូវបានគេសម្លាប់ ឬបញ្ចុះបញ្ចូលមិនឱ្យផ្តល់សក្ខីកម្មប្រឆាំងអ្នកជួញដូរមនុស្ស។ ក្រៅពីនេះ មានការសន្មតថា ជនរងគ្រោះដែលអាចដើរហើរដោយសេរី នឹងសម្រេចចិត្តមិនបានគ្រប់ជ្រុងជ្រោយ រត់ចេញ និងត្រឡប់ទៅរកអ្នកជួញដូរមនុស្ស និង/ឬទម្រង់ ឬស្ថានភាពការងារបែបកេងប្រវ័ញ្ច។

សន្និទានភាពនៃការការពារ អះអាងថា អ្នកដែលត្រូវបានជួញដូរ ត្រូវស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពដើម្បីបង្ការមិនឱ្យពួកគេបង្កគ្រោះថ្នាក់លើខ្លួនឯង ឬអ្នកដទៃ។ ជនរងគ្រោះជាច្រើនមានបញ្ហាសុខភាពផ្លូវចិត្ត និងស្មារតី ដោយសារការរំលោភបំពាន និងការប៉ះទង្គិចផ្លូវចិត្ត។ អង្គការមិនមែនរដ្ឋាភិបាលមួយដែលចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ លើកឡើងពីភាពចាំបាច់ក្នុងការឃ្លាំមើលជិតដល់លើជនរងគ្រោះមួយចំនួន ដែលបានប្រព្រឹត្តហិង្សា ងាយនឹងបង្កគ្រោះថ្នាក់លើខ្លួនឯង ឬត្រូវបានបង្ខំឱ្យប្រឡូកក្នុងការរួមភេទច្រើនហួសហេតុ (ការញៀននឹងការរួមភេទដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព)។ សន្និទានភាពនៃការការពារ ផ្អែកតាមការបំភិតបំភ័យ និងការគំរាមកំហែងជាច្រើនលើកច្រើនសាលើជនរងគ្រោះ (ក៏ដូចជាបុគ្គលិកក្នុងមណ្ឌលសុវត្ថិភាព) ពីសំណាក់អ្នកជួញដូរមនុស្ស និងអ្នកដទៃទៀត ជាពិសេសប្រសិនបើពួកគេពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសដែលមានអង្គការចាត់តាំង។

បុគ្គលិកសង្គមកិច្ច និងអ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាព សម្តែងការព្រួយបារម្ភលើភាពអាចអនុវត្តបាននៃការធានាសុវត្ថិភាព និងសុខុមាលភាពរបស់អតិថិជន ប្រសិនបើជនរងគ្រោះមិនរស់នៅក្នុងមណ្ឌលសុវត្ថិភាព។ ភាពចាំបាច់នៃការការពារ កាន់តែមានភាពជ្រាលជ្រៅ នៅពេលនិយាយពីកុមារ និងអនីតិជន ដែលមិនមានទីភ្នាក់ងារដូចមនុស្សពេញវ័យ និងងាយរងគ្រោះដោយសារការបោកបញ្ឆោត និងការរំលោភបំពាន។ ភាគីពាក់ព័ន្ធជាច្រើនទទួលស្គាល់ថា សេរីភាពរបស់ជនរងគ្រោះក្នុងការចេញចូលមណ្ឌលសុវត្ថិភាពបានគ្រប់ពេលដែលពួកគេចង់ គឺមិនអាចទៅរួចនោះទេ។ អ្នកចូលរួមជាជនជាតិឡាវម្នាក់ លើកឡើងពីភាពចាំបាច់នៃការគ្រប់គ្រងការដើរហើររបស់ជនរងគ្រោះថា "យើងមានការទទួលខុសត្រូវផ្លូវច្បាប់លើជីវិតរបស់ពួកគេក្នុងពេលដែលពួកគេស្នាក់នៅជាមួយយើង"។ នេះជាការយល់ឃើញដែលស៊ីសង្វាក់គ្នានឹងការយល់ឃើញរបស់អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពជាច្រើន នៅក្នុងប្រទេសជាសមាជិកអាស៊ាន។ ភាគីពាក់ព័ន្ធគូសបញ្ជាក់ជាច្រើនលើកច្រើនសាពីបញ្ហាប្រឈមក្នុងការរក្សាតុល្យភាពរវាងតម្រូវការចម្រុះដែលពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព និងស្វ័យភាពរបស់ជនរងគ្រោះ។

ទោះបីជាមានចេតនាល្អក៏ដោយ ក៏គោលវិធីមួយដែលផ្អែកលើសនិទានភាពនៃការការពារ អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសម្រេចចិត្ត និងស្វ័យភាពរបស់ជនរងគ្រោះ។ ការស្រាវជ្រាវស្តីពីការរស់នៅរបស់ស្ត្រីនៅក្នុងមណ្ឌលសុវត្ថិភាព បង្ហាញថា គេច្រើនតែយល់ថា ស្ត្រីទាំងនោះមិនមានសមត្ថភាពប្រើប្រាស់ឆន្ទានុសិទ្ធិផ្ទាល់ខ្លួន និងត្រូវបានដកហូតសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯង[២០]។ ស្ថានភាពទាំងនេះអាចបង្កើតឡើងវិញនូវការបង្ខិតបង្ខំ និងការបដិសេធទីភ្នាក់ងារដែលបង្កើតឡើងដោយអ្នកជួញដូរមនុស្ស។ ស្ថានភាពនេះក៏បញ្ជាក់គ្នានឹងម៉ូដែលនៃការថែទាំផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត ដែលមានគោលបំណងស្តារស្វ័យភាព និងដោះស្រាយភាពអយុត្តិធម៌ ដែលភាគីពាក់ព័ន្ធជាច្រើននៅអាស៊ាន ប្តេជ្ញាអនុវត្តឱ្យបានផងដែរ។

ជាមួយគ្នានេះដែរ សនិទានភាពនៃការការពារបានរារាំងមិនឱ្យភាគីពាក់ព័ន្ធអនុវត្តដោយស៊ីសង្វាក់គ្នានូវម៉ូដែលមណ្ឌលសុវត្ថិភាពផ្អែកលើសិទ្ធិ។ ជនរងគ្រោះដែលមិនទទួលបានការការពារ ឬការទ្រទ្រង់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួន នឹងបន្តរត់ចេញពីមណ្ឌលសុវត្ថិភាព។ ដោយមិនគិតថាតើមណ្ឌលសុវត្ថិភាពត្រូវបានចាត់ទុកថា "បើកចំហរ" "បិទជិត" ឬ "ពាក់កណ្តាលបិទជិត" នោះទេ មណ្ឌលសុវត្ថិភាពដែលផ្អែកលើសិទ្ធិ មិនគួររំលោភសេរីភាពដើរហើរ ឬសិទ្ធិសេរីភាពរបស់ជនរងគ្រោះឡើយ។ ជនរងគ្រោះគួរតែអាចចេញពីមណ្ឌលសុវត្ថិភាព ប្រសិនបើការធ្វើដូច្នេះមានសុវត្ថិភាពសម្រាប់ពួកគេ។

*ស្ត្រីមួយចំនួនត្រូវបានផ្ទេរទៅមណ្ឌលថែទាំ ដែលមានលក្ខណៈដូចមន្ទីរឃុំឃាំង។នៅទីនេះ ចល័តភាពរបស់បុគ្គលស្នាក់នៅក្នុងមណ្ឌលត្រូវបានរឹតត្បិត។ ស្ត្រីជំទាស់នឹងគំនិតដែលតម្រូវឱ្យពួកគេស្នាក់នៅទីនោះ ព្រោះពួកគេព្រួយបារម្ភខ្លាចមិនអាចចាកចេញពីទីនោះ ឬទាក់ទងទៅគ្រួសារបាន។ ក្នុងចំណោមនេះ ស្ត្រីជាច្រើនជាអ្នកទំនុកបម្រុងគ្រួសារ ហើយគ្រួសារពឹងផ្អែកលើពួកគេដើម្បីបំពេញតម្រូវការចាំបាច់។ ពួកគេចាប់ផ្តើមប្រព្រឹត្តបែបគឃ្លើនដាក់បុគ្គលិក ព្រោះពួកគេមិនបានយល់ព្រមស្នាក់នៅទីនោះទេ។*

*--- ពួកគេមិនទុកចិត្តបុគ្គលិកសង្គមកិច្ច ដោយសាររបៀបដែលពួកគេត្រូវបានសម្ភាសន៍ ឬប្រព្រឹត្តចំពោះដោយបុគ្គលិកមិនស្លៀកពាក់ឯកសណ្ឋាននៅប៉ុស្តិ៍ប៉ូលីស (បុគ្គលិកសង្គមកិច្ច និងជាប្រធានអង្គភាពយេនឌ័រ និងការអភិវឌ្ឍនៃផ្នែកគ្រប់គ្រង និងផ្តល់សេវាសង្គម នៃកម្មវិធី Pantawid Pamilyang Pilipino ប្រទេសហ្វីលីពីន សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១)។*



សនិទានភាពនៃ***ជំនួយ*** សន្មតថា ការគាំទ្រ និងសេវា ដូចជា ការថែទាំផ្នែកចិត្តសង្គម ជំនួយផ្លូវច្បាប់ និងការអភិវឌ្ឍជំនាញសម្រាប់អ្នកដែលត្រូវបានជួញដូរ គឺមានផ្ដល់ជូន និងគួរផ្ដល់ជូនតែក្នុងបរិបទមណ្ឌលសុវត្ថិភាពប៉ុណ្ណោះ។ តាមការយល់ឃើញរបស់អ្នកផ្ដល់សេវាមួយចំនួន កន្លែងដែលមានការគ្រប់គ្រង ដូចជា មណ្ឌលសុវត្ថិភាព អាចជាកន្លែងសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងការព្យាបាល និងស្ដារឡើងវិញ។ សម្រាប់អ្នកដែលទាមទារការថែទាំឯកទេស មណ្ឌលសុវត្ថិភាពត្រូវបានគេចាត់ទុកជាកន្លែងល្អមួយសម្រាប់ការទទួលបានសេវាទាំងនេះ ពោលគឺសេវាដែលពួកគេអាចនឹងមិនទទួលបាន ប្រសិនបើពួកគេរស់នៅក្រៅមណ្ឌលសុវត្ថិភាព។ ទោះជាយ៉ាងណា ប្រទេសថៃបាន និងកំពុងដេញដោលសនិទានភាពនៃជំនួយ ទាំងជាមួយមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋ និងមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលផ្ដល់ជំនួយ និងសេវាដល់ជនរងគ្រោះ ទោះបីជាពួកគេមិនចង់ស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពក៏ដោយ។ អ្វីដែលសំខាន់គឺការវាយតម្លៃហានិភ័យលម្អិត និងការធានាថាជនរងគ្រោះមានសុវត្ថិភាព ប្រសិនបើពួកគេសម្រេចមិនស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។

សនិទានភាពនៃ***ការផ្ដន្ទាទោស*** រកឃើញភាពស្របច្បាប់ក្នុងអង្គហេតុដែលលើកឡើងថា វត្តមានរបស់ជនរងគ្រោះ-សាក្សី នៅតែជាលក្ខខណ្ឌតម្រូវមួយក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសសមាជិកអាស៊ានជាច្រើន។ ដូច្នេះ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានដាក់ឱ្យស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពសម្រាប់រយៈពេលទាំងមូលនៃដំណើរការផ្លូវច្បាប់ ដើម្បីអាចកោះហៅពួកគេបានគ្រប់ពេលសម្រាប់ការផ្ដល់ភស្តុតាងចោទប្រកាន់ប្រឆាំងនឹងជនល្មើស។ ក្រៅពីនេះ ពួកគេត្រូវបានរារាំងមិនឱ្យចាកចេញពីមណ្ឌលសុវត្ថិភាព ព្រោះពួកគេមិនសូវចង់បន្តសហការជាមួយស្ថាប័នអនុវត្តន៍ច្បាប់ និងទីភ្នាក់ងារយុត្តិធម៌ បន្ទាប់ពីពួកគេបានជួបជុំគ្រួសារវិញ។ ភាគីពាក់ព័ន្ធលើកឡើងថា ការលំបាកផ្នែកហិរញ្ញវត្ថុ ការប្រែប្រួលស្ថានភាពសង្គម និងស្ថានភាពផ្ទាល់ខ្លួន សម្ពាធពីការមាក់ងាយ និងភាពតានតឹងដោយសារការប៉ះទង្គិចផ្លូវចិត្ត ជាមូលហេតុមួយចំនួនដែលធ្វើឱ្យជនរងគ្រោះបោះបង់ដំណើរការផ្លូវច្បាប់។

ការពន្យារពេលក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌធ្វើឱ្យជនរងគ្រោះជាច្រើនបន្តស្ថិតក្រោមការឃុំគ្រង ដូចជាការស្ថិតនៅក្នុងមណ្ឌលសុវត្ថិភាព។ សេចក្តីសម្រេចអាចធ្វើឡើងក្រោយរយៈពេលជាច្រើនឆ្នាំ ដោយមិនមានការធានាលទ្ធផលវិជ្ជមានសម្រាប់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។ ដោយកត់សម្គាល់ពីចំណុចនេះ ប្រទេសជាសមាជិកអាស៊ានមួយចំនួន បានឈានដល់ការញែកដាច់ពីគ្នារវាងការការពារជនរងគ្រោះនិងឆន្ទៈរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងការផ្តន្ទាទោស។ ប្រទេសហ្វីលីពីន និងថៃ សុទ្ធតែជាឧទាហរណ៍ល្អនៃករណីដែលជនរងគ្រោះមិនចាំបាច់ត្រូវស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព ដើម្បីរង់ចាំកិច្ចដំណើរនីតិវិធីនៃការផ្តន្ទាទោស។

ភាគីពាក់ព័ន្ធម្នាក់ដែលជាជនជាតិថៃលើកឡើងថា មានការសន្មតជាយូរមកហើយថា ជនរងគ្រោះនឹងរត់គេចពីការស៊ើបអង្កេត និងកិច្ចដំណើរការនីតិវិធី ប្រសិនបើពួកគេអាចធ្វើបាន ដូច្នេះ វាធ្វើឱ្យមន្ត្រីអនុវត្តន៍ច្បាប់នៅថៃចង់ដាក់ជនរងគ្រោះ-សាក្សី នៅក្នុងមណ្ឌលសុវត្ថិភាព។

តាំងពីពេលនោះមក ប្រទេសថៃបានកែលម្អប្រព័ន្ធតុលាការ ដើម្បីអនុញ្ញាតឱ្យមានការពិចារណា និងការផ្តល់ការបង់ប្រាក់ជានានៅក្រៅឃុំដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ពីមុន មានការលើកឡើងថា សំណើសុំបង់ប្រាក់ជានានៅក្រៅឃុំ គឺមិនងាយស្រួលនោះទេ។ ក្នុងការស្វែងរកដំណោះស្រាយដែលមាននិរន្តរភាព ភាគីពាក់ព័ន្ធនៅប្រទេសថៃបានពិភាក្សាពីលទ្ធភាពដែលក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជន (MSDHS) ដែលជាទីភ្នាក់ងារដឹកនាំការផ្តល់ជំនួយ និងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចជួយសម្របសម្រួលឱ្យជនរងគ្រោះបានរួចផុតពីកិច្ចដំណើរការនីតិវិធី និងដំណើរការតុលាការ។ អភិក្រមនេះមានន័យថា ជនរងគ្រោះមិនត្រូវបានគេដាក់ឱ្យស្ថិតក្នុងមណ្ឌលសុវត្ថិភាពដោយមិនស្ម័គ្រចិត្ត និងដោយមិនសមស្របក្នុងរយៈពេលយូរនោះទេ ដែលទីបំផុត វានឹងកាត់បន្ថយទឹកចិត្តរបស់ជនរងគ្រោះក្នុងការចូលរួមសហការផ្តន្ទាទោសជនល្មើសនៅគ្រប់ករណី។

# ៣.៤ ឆ្ពោះទៅរកមណ្ឌលសុវត្ថិភាពដែលកាន់តែមានបរិយាបន្ន

របាយការណ៍ឆ្នាំ២០១៨របស់កម្មវិធី ASEAN-ACT រកឃើញថា ការអនុវត្តក្នុងមណ្ឌលសុវត្ថិភាពនៅអាស៊ាន មានលក្ខណៈផ្អែកតាមយេនឌ័របំផុត[២១]។ ការអនុវត្តយ៉ាងទូលំទូលាយក្នុងមណ្ឌលសុវត្ថិភាពឆ្លុះបញ្ចាំងពីលទ្ធផលរកឃើញទាំងនេះ មានជាអាទិ៍ ការបន្តខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសមស្របនៅក្នុងមណ្ឌលសុវត្ថិភាពសម្រាប់ជនពិការ ជនរងគ្រោះជាជនបរទេស និងអ្នកមានយេនឌ័រផ្សេងៗ។ ភាគីពាក់ព័ន្ធមួយចំនួនលើកឡើងថា ពួកគេត្រូវបដិសេធ និងបញ្ជូនបុរសដែលជាជនរងគ្រោះដោយអំពើជួញដូរឱ្យត្រឡប់ទៅផ្ទះវិញ ព្រោះពួកគេមិនមានសមត្ថភាពផ្តល់មណ្ឌលសុវត្ថិភាពដល់បុរសទាំងនោះ។ ក្នុងមណ្ឌលសុវត្ថិភាពជាច្រើននៅអាស៊ាន ស្ត្រីដែលស្នាក់នៅក្នុងមណ្ឌល នៅតែទទួលបានការបណ្តុះបណ្តាលលើជំនាញបែបប្រពៃណីនៅក្នុងគ្រួសារសម្រាប់ស្ត្រី ដូចជាសិប្បកម្ម ការដេរប៉ាក់ ការចម្អិន ជាជាងការផ្អែកទៅលើជំនាញដែលកាន់តែមានចំណាប់អារម្មណ៍សមស្របនឹងផលប្រយោជន៍ សមត្ថភាព ឬជំនាញរបស់បុគ្គល ឬជាមួយតម្រូវការទីផ្សារការងារ។ តាមរយៈការរឹតត្បិតឱកាសវិជ្ជាជីវៈត្រឹមជំនាញក្នុងគ្រួសារ កម្មវិធីទាំងនេះអាចកាត់បន្ថយ ជាជាងបង្កើនស្វ័យភាព និងវិបុលភាពសេដ្ឋកិច្ចនាពេលអនាគតរបស់ស្ត្រី និងក្មេងស្រីដែលត្រូវបានគេជួញដូរ។

ប្រទេសថៃកំពុងអនុវត្តអភិក្រមបែបបរិយាបន្នសម្រាប់ការផ្តល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ដោយកត់សម្គាល់ថាក្រុមផ្សេងៗមានតម្រូវការខុសៗគ្នាទៅតាមយេនឌ័រ និងអាយុ MSDHS បានបង្កើតមណ្ឌលសុវត្ថិភាពចំនួន៩ (មណ្ឌលសុវត្ថិភាព ៤ សម្រាប់ស្ត្រី និងក្មេងស្រី មណ្ឌលសុវត្ថិភាព ៤ សម្រាប់បុរសដែលមានអាយុលើស ១៥ ឆ្នាំ និងមណ្ឌលសុវត្ថិភាព ១ សម្រាប់ក្មេងប្រុសដែលមានអាយុក្រោម ១៥ ឆ្នាំ)។ ក្រសួងបានចាប់ដៃគូសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការដំណើរការមណ្ឌលសុវត្ថិភាពដោយអង្គការផ្ទាល់ ដើម្បីផ្តល់ជម្រើសផ្សេងក្រៅពីមណ្ឌល



សុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋ ហើយជនរងគ្រោះមានសេរីភាពក្នុងការជ្រើសរើសមណ្ឌលសុវត្ថិភាពដែលពួកគេពេញចិត្ត។ ក្រៅពីនេះ ក្រសួងមានមណ្ឌលសុវត្ថិភាពបណ្តោះអាសន្ន នៅតាមខេត្ត ដែលអាចផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្នរយៈពេល ៣-៧ ថ្ងៃ មុននឹងបញ្ជូនជនរងគ្រោះទៅមណ្ឌលសុវត្ថិភាពអចិន្ត្រៃយ៍។

ដូចគ្នានេះដែរ ក្រុមប្រឹក្សាអន្តរទីភ្នាក់ងារហ្វីលីពីនប្រឆាំងអំពើជួញដូរមនុស្ស (IACAT) បានអនុវត្ត Tahanan ng Inyong Pag-Asa ឬមជ្ឈមណ្ឌល T.I.P នៅខែ ធ្នូ ឆ្នាំ ២០២០។ នេះជាមណ្ឌលសុវត្ថិភាពដំបូងគេរបស់ IACAT និងជាមជ្ឈមណ្ឌលផ្តល់សេវាចម្រុះដែលបំពេញតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ មជ្ឈមណ្ឌលនេះជាមណ្ឌលសុវត្ថិភាពបណ្តោះអាសន្នសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានសង្គ្រោះ និងមកទល់បច្ចុប្បន្ន បានជួយស្ត្រី ២៤ នាក់ បុរស ៦ នាក់ ក្មេងស្រី ១៤ នាក់ និងក្មេងប្រុស ១០ នាក់។

ក្រសួងស្ត្រី គ្រួសារ និងអភិវឌ្ឍន៍សហគមន៍ម៉ាឡេស៊ីបានបង្កើតមណ្ឌលចំនួន ១០ សម្រាប់ផ្តល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ មណ្ឌលសុវត្ថិភាពចំនួន ៨ គ្រប់គ្រងដោយរដ្ឋ (៥ សម្រាប់ស្ត្រី ២ សម្រាប់កុមារនិង ១ សម្រាប់បុរស) និងមណ្ឌលសុវត្ថិភាពចំនួន ២ គ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល (សម្រាប់ស្ត្រី និងកុមារ)។

ប្រទេសថៃបាន និងកំពុងរិះរកវិធីផ្តល់ការថែទាំ និងការការពារកាន់តែប្រសើរដល់ជនរងគ្រោះដែលជាក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTQI) (ស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស ចំណង់ផ្លូវភេទទាំងពីរភេទ ការផ្លាស់ប្តូរភេទ អ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរភេទ អ្នកដែលមិនកំណត់ថាខ្លួនជាមនុស្សប្រុស ឬមនុស្សស្រី)។ ក្រោយការពិគ្រោះយោបល់ជាមួយក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា MSDHS សម្រេចមិនបង្កើតមណ្ឌលសុវត្ថិភាពមួយក្នុងខេត្តឈៀងរ៉ៃសម្រាប់ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា ដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សទេ។ ផ្ទុយទៅវិញ មណ្ឌលសុវត្ថិភាពដែលមានស្រាប់ត្រូវបានលើកទឹកចិត្ត/តម្រូវឱ្យផ្តល់ចន្លោះឯកជន និងមានសុវត្ថិភាពដល់ជនរងគ្រោះដែលជាមនុស្សស្រឡាញ់ភេទដូចគ្នា។ ទន្ទឹមនឹងនេះ អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពទាំងអស់នឹងទទួលការបណ្តុះបណ្តាលស្តីពីរបៀបប្រព្រឹត្តចំពោះជនរងគ្រោះជាមនុស្សស្រឡាញ់ភេទដូចគ្នា ដោយប្រើប្រាស់ម៉ូឌុលតែមួយដែលត្រូវបានបង្កើតឡើងសម្រាប់មណ្ឌលសុវត្ថិភាពនៅខេត្តឈៀងរ៉ៃ។ អ្នកនាំពាក្យម្នាក់មកពី MSDHS និយាយថា វិធានការទាំងនេះគឺដើម្បីលើកទឹកចិត្តឱ្យមនុស្សស្រឡាញ់ភេទដូចគ្នាកាន់តែច្រើនមកបង្ហាញអត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

នៅសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ភាគីពាក់ព័ន្ធទាំងអស់នៅអាស៊ានសុទ្ធតែលើកឡើងថា ការថែទាំកុមារដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សគឺជាបញ្ហាប្រឈមមួយ។ បញ្ហានេះមានភាពស្រួចស្រាវបំផុតសម្រាប់កុមារដែលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងត្រូវការការថែទាំ និងប្រព្រឹត្តិកម្មឯកទេសក្នុងរយៈពេលយូរ ក៏ដូចជាកុមារដែលជាជនមិនមានប្រទេស។ អ្នកផ្តល់មណ្ឌលសុវត្ថិភាពលើកឡើងពីភាពទាល់ច្រកដោយសារកង្វះបុគ្គលិកដែលមានគុណវុឌ្ឍិ និងជំនួយហិរញ្ញវត្ថុសម្រាប់ការថែទាំកុមារទាំងនេះ។ ភាគីពាក់ព័ន្ធដែលជាជនជាតិហ្វីលីពីន លើកឡើងថា ពួកគេមានភាពចម្រូងចម្រាស់ពាក់ព័ន្ធនឹងថាតើត្រូវពន្យារពេលមិនឱ្យអនីតិជនចាកចេញពីមណ្ឌលសុវត្ថិភាពដើម្បីការពារសុវត្ថិភាពរបស់ពួកគេ ឬអនុញ្ញាតឱ្យពួកគេសម្រេចចិត្តដោយខ្លួនឯង (ដូចជា ការត្រឡប់ទៅវង្គសាល និងអាចត្រូវបានគេរំលោភសេពសន្ថវៈ)។ ផ្អែកតាមបទពិសោធន៍របស់ពួកគេជាទូទៅ ស្ត្រី និងក្មេងស្រីដែលត្រូវបាន "សង្គ្រោះ" ពីកន្លែងកំសាន្ត នឹងត្រឡប់ទៅកន្លែងធ្វើការវិញក្រោយពេលចាកចេញពីមណ្ឌលសុវត្ថិភាព។ ដើម្បីបញ្ចៀសបញ្ហានេះ អ្នកផ្តល់មណ្ឌលសុវត្ថិភាព និងបុគ្គលិកសង្គមកិច្ច ព្យាយាមបញ្ចុះបញ្ចូលមិនឱ្យជនរងគ្រោះ ជាពិសេសកុមារ ចាកចេញពីមណ្ឌលសុវត្ថិភាពឆាប់ហ័សពេកនោះទេ និងប្រាប់ពួកគេពីជម្រើសផ្សេងៗដែលពួកគេមាន និងសេវាដែលពួកគេអាចទទួលបាននៅក្នុងមណ្ឌលសុវត្ថិភាព។



រូបថត ៖ មជ្ឈមណ្ឌលគាំពារសុខុមាលភាពជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅខេត្តប៉ាក់ធុមថានី ប្រទេសថៃ (ក្រេឌីត ៖ Rawena Russell)

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រសួងសុខុមាលភាពសង្គម និងការអភិវឌ្ឍហ្វីលីពីន (DSWD) កំពុងសហការគ្នាបង្កើតម៉ូដែលនៃការថែទាំដោយឪពុកម្តាយធម៌ សម្រាប់ជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទតាមអ៊ីនធឺណិត និងការកេងប្រវ័ញ្ចកុមារ (OSAEC)។ ប្រទេសហ្វីលីពីនត្រូវបានកំណត់ជាប្រទេសប្រភពចម្បងមួយនៃ OSAEC ហើយវិបត្តិកូវីដ-១៩ បានធ្វើឱ្យនិន្នាការនេះរីកធំឡើង[២២]។ ម៉ូដែលនៃការថែទាំដោយឪពុកម្តាយធម៌ ផ្តោតលើជនរងគ្រោះដែលនៅក្មេង និងបងប្អូនបង្កើតដែលមានយេនឌ័រផ្សេងៗ/ចម្រុះ។ ម៉ូដែលនេះដោះស្រាយបញ្ហាកង្វះហេដ្ឋារចនាសម្ព័ន្ធមណ្ឌលសុវត្ថិភាពនៅហ្វីលីពីនបច្ចុប្បន្ន ដើម្បីសម្រួលដល់ក្រុមមានយេនឌ័រចម្រុះ។

មានមូលដ្ឋាននៅខេត្តឈៀងម៉ៃ មូលនិធិផ្សារភ្ជាប់គ្រួសារ[២៣] បានដំណើរការមណ្ឌលកុមារកំព្រាមួយសម្រាប់កុមារងាយរងគ្រោះនៅ Ban Sanrak។ ក្នុងផ្ទះស្នាក់នោះ មានកុមារមិនលើស ៦ នាក់ ហើយក្នុងបន្ទប់នីមួយៗ មានកុមារមិនលើស ៣ នាក់។ បុគ្គលិកមណ្ឌលសុវត្ថិភាពបានរៀបចំសកម្មភាពផ្សេងៗសម្រាប់កុមារ ដូចជា ការទៅមើលកុន។ មូលនិធិនេះផ្តោតលើការជួយដល់កុមារដែលត្រូវបានវាយតម្លៃថាជាកុមារកំព្រាពិតប្រាកដ និងកុមារដែលត្រូវបានឪពុកម្តាយបោះបង់ចោល រងការរំលោភបំពាន និងការមិនយកចិត្តទុកដាក់ និងកុមារដែលមិនអាចត្រឡប់ទៅគ្រួសារវិញបាន។ នឹងមានការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការថែទាំកុមារដល់បុគ្គលិកដែលធ្វើការងារពាក់ព័ន្ធនឹងការកសាងទំនាក់ទំនងល្អជាមួយកុមារ ក្នុងរយៈពេល ៣-៦ ខែដំបូងដែលកុមារចូលទៅស្នាក់ក្នុងផ្ទះនោះ។ មូលនិធិនេះផ្តោតលើការលើកទឹកចិត្តឱ្យកុមារមានការគោរពចំពោះអ្នកដទៃ និងបង្កើនតម្លៃផ្ទាល់ខ្លួន ក្លាយជាពលរដ្ឋដែលមានការទទួលខុសត្រូវ និងមានឥរិយាបថវិជ្ជមានចំពោះជីវិត។ អភិក្រមដែលយកចិត្តទុកដាក់ចំពោះកុមារ ត្រូវបានយកមកអនុវត្តក្នុងការអភិវឌ្ឍផែនការសម្រាប់កុមារម្នាក់ៗ។ កុមារចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការ ដោយកុមារមានអាយុច្រើន ជាអ្នកសម្រេចចិត្តដោយខ្លួនឯងពីអ្វី/កន្លែងដែលពួកគេចង់សិក្សារៀនសូត្រ។

[២០] Cordisco Tsai, L., Lim, V., Nhanh, C., & Namy, S. (2022). "They Did Not Pay Attention or Want to Listen When We Spoke": Women's Experiences in a Trafficking-Specific Shelter in Cambodia. Affilia, 37(1), 151–168.

[២១] Marika McAdam (២០១៨) សេរីភាពបំលាស់ទីសម្រាប់អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ ការវិភាគច្បាប់ គោលនយោបាយ និងការអនុវត្តក្នុងតំបន់អាស៊ាន។ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។

[២២] "Study: Philippines a global hotspot for online child abuse". Associated Press. 21 May 2020. See https://abcnews. go.com/International/wire Story/study-philippines-global-hot-spot-online-child-abuse-70804205

[២៣] សូមមើល https://fcfthailand.org/live/portfolio/bansanrak/

[២៤] ព័ត៌មាននេះសុក្រឹត គិតត្រឹមថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២១។

[២៥] ព័ត៌មាននេះសុក្រឹត ក្នុងអំឡុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១។

[២៦] Cordisco Tsai, L., Lim, V., Nhanh, C., & Namy, S. (2022). "They Did Not Pay Attention or Want to Listen When We Spoke": Women's Experiences in a Trafficking-Specific Shelter in Cambodia. Affilia, 37(1), 151–168.

[២៧] សូមមើល អាស៊ាន (២០២៣) ឯកសារមគ្គុទេសក៏អាស៊ានស្តីពីការមិនបង្កគ្រោះថ្នាក់ សម្រាប់អ្នកឆ្លើយតបជួរមុខ៖ ការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ហ្សាការតា៖ លេខាធិការដ្ឋានអាស៊ាន។

# ៣.៥ បញ្ហាប្រឈម ក្រៅពីមណ្ឌលសុវត្ថិភាពបិទជិត និងសេរីភាព បំលាស់ទីរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ បានពិភាក្សាពីបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធនឹងការថែទាំ និងការការពារជនរងគ្រោះ។ ពីខាងដើម ឯកសារនេះពណ៌នាថា កង្វះមណ្ឌលសុវត្ថិភាព និងសេវាគាំទ្រសម្រាប់ជនរងគ្រោះភេទប្រុស និងក្រុមងាយរងគ្រោះផ្សេងទៀត ជាគម្លាតដ៏ធំក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងបញ្ហារសើបដែលពាក់ព័ន្ធនឹងរបៀបដែលជនរងគ្រោះដោយអំពើជួញដូរមនុស្ស គួរ ឬអាចប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់ពួកគេ។ ផ្នែកនេះរៀបរាប់ពីបញ្ហាប្រឈមដែលពាក់ព័ន្ធផ្សេងទៀតនៅក្នុងមណ្ឌលសុវត្ថិភាព ដូចជា បញ្ហាដែលបណ្តាលមកពីវិបត្តិកូវីដ-១៩ ដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធនៅអាស៊ាន។

## ៣.៥.១ ការបង្អាក់ដោយវិបត្តិកូវីដ-១៩

វិបត្តិកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើលទ្ធភាពទាន់ពេលវេលារបស់ជនរងគ្រោះក្នុងការទទួលបានមណ្ឌលសុវត្ថិភាព និងសេវាគាំទ្រផ្សេងទៀត។ ក្រៅពីការរឹតត្បិតលើចល័តភាព និងកំណើនបន្ទុកការងារដែលពាក់ព័ន្ធនឹងការអនុលោមតាមបទបញ្ញត្តិ និងពិធីសារថ្មីៗ អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពនៅអាស៊ាន បានលើកឡើងពីបញ្ហាជាក់លាក់មួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការផ្តល់ការថែទាំ និងការការពារដែលមានគុណភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

បញ្ហាប្រឈមមួយដែលបានលើកឡើងគឺ តម្រូវការមជ្ឈមណ្ឌលសំចត ដែលដើរតួនាទីជាកន្លែងរក្សាទុកជនរងគ្រោះសម្រាប់ការធ្វើតេស្តរកជំងឺកូវីដ-១៩។ កង្វះធនធានហិរញ្ញវត្ថុក្នុងរដ្ឋាភិបាលត្រូវបានលើកឡើងជាមូលហេតុមួយដែលធ្វើឱ្យចំនួនមជ្ឈមណ្ឌលសំចតមិនអាចបំពេញតម្រូវការជាក់ស្តែងបាន។ បញ្ហាថាតើនរណាជាអ្នកបង់ថ្លៃធ្វើតេស្តរកជំងឺកូវីដ-១៩ រួមទាំងថ្លៃធ្វើតេស្តរហ័ស សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានលើកឡើងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិជាច្រើន។ ភាគីពាក់ព័ន្ធម្នាក់នៅឥណ្ឌូនេស៊ីលើកឡើងថា ភាពមិនសូវច្បាស់លាស់ជុំវិញបញ្ហានេះ បានធ្វើឱ្យជនរងគ្រោះជាច្រើននាក់ត្រាំត្រែងក្នុងមជ្ឈមណ្ឌលសំចតជាច្រើនខែ។

វិធានការកាត់បន្ថយភាពណែនតាន់តាប់នៅក្នុងមណ្ឌលសុវត្ថិភាព មានន័យថា បច្ចុប្បន្ន សមត្ថភាពរបស់មណ្ឌលសុវត្ថិភាពជាច្រើន គឺមានការថយចុះ។ ក្រៅពីនេះ មណ្ឌលសុវត្ថិភាពមួយចំនួនបានលើកឡើងពីបញ្ហាប្រឈមក្នុងការរៃអង្គាសមូលនិធិ ដែលបង្កឡើងដោយវិបត្តិកូវីដ-១៩ ព្រោះរដ្ឋាភិបាល និងម្ចាស់ជំនួយ បង្វែរជំនួយទៅរកគំនិតផ្តួចផ្តើមសុខភាពសាធារណៈ។ ដូច្នេះ មណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ត្រូវពឹងផ្អែកលើការបរិច្ចាគពីឯកជនកាន់តែខ្លាំង ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការទំនុកបម្រុងមណ្ឌលសុវត្ថិភាព និងសេវា។ ស្ថានភាពនេះបានដាក់សម្ពាធកាន់តែខ្លាំងលើអ្នកផ្តល់សេវា។



បញ្ហាមួយទៀតពាក់ព័ន្ធនឹងស្ថានភាពនៃការចាក់វ៉ាក់សាំងរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ការចាក់វ៉ាក់សាំងមិនមែនជាលក្ខខណ្ឌតម្រូវនោះទេ នៅក្នុងប្រទេសសមាជិកអាស៊ានភាគច្រើន លើកលែងតែប្រទេសឥណ្ឌូនេស៊ីដែលប្រកាសពីកាតព្វកិច្ចចាក់វ៉ាក់សាំងសម្រាប់ពលរដ្ឋទាំងអស់ដែលមានលក្ខណៈសម្បត្តិ នៅខែកុម្ភៈ ឆ្នាំ ២០២១[២៤]។ អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពរងសម្ពាធក្នុងការរិះរកវិធីធ្វើយ៉ាងណាគ្រប់គ្រងបុគ្គលស្នាក់នៅក្នុងមណ្ឌល (ទាំងចាស់ទាំងថ្មី) ដែលបដិសេធមិនចាក់វ៉ាក់សាំងកូវីដ-១៩។ ទោះបីជាច្បាប់តម្រូវឱ្យចាក់វ៉ាក់សាំងក៏ដោយ ក៏អ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាពនៅតែត្រូវការការណែនាំ ស្តីពីរបៀបបញ្ចុះបញ្ចូលបុគ្គលស្នាក់នៅក្នុងមណ្ឌលដែលជំទាស់នឹងការចាក់វ៉ាក់សាំង (ដែលសំអាងលើហេតុផលផ្ទាល់ខ្លួន និងហេតុផលវប្បធម៌) ឱ្យចាក់វ៉ាក់សាំង។

ក្នុងប្រទេសហ្វីលីពីន មណ្ឌល Tanglaw Buhay និយាយថា ជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់លើកុមារដែលទើបបញ្ជូនមកថ្មី ព្រោះពួកគេត្រូវឆ្លងកាត់ការធ្វើតេស្ត PCR ដើម្បីបង្ហាញលទ្ធផលអវិជ្ជមាន មុននឹងចូលទៅក្នុងមណ្ឌល។ លក្ខខណ្ឌតម្រូវនេះបានបង្កើនចំណាយបន្ថែមទៀតសម្រាប់ប្រតិបត្តិការរបស់មណ្ឌល។ ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសហ្វីលីពីន មិនអាចផ្តល់សេវាមិនគិតថ្លៃសម្រាប់ការយកសំណាក ដល់មនុស្សគ្រប់រូបបានឡើយ។ ដូច្នេះ លក្ខខណ្ឌតម្រូវឱ្យធ្វើតេស្តមួយចំនួន បានក្លាយជាបន្ទុករបស់មណ្ឌលសុវត្ថិភាព។ ការងាកទៅរកគោលវិធីថ្មីនៃការរៀនសូត្រតាមអនឡាញ ដែលចែកជាម៉ូឌុលសម្រាប់កុមារ មានន័យថា បុគ្គលិកក្នុងមណ្ឌលសុវត្ថិភាពត្រូវចំណាយពេល និងថាមពលកាន់តែច្រើនដើម្បីបង្វឹកបង្ហាត់កុមារដែលមិនអាចសម្របខ្លួនបានលឿន និងតាមទាន់ទម្រង់ថ្មីនៃការរៀនសូត្រនេះ។ ក្រៅពីនេះ បណ្តាញអ៊ីនធឺណិតមិនរលូន បានបង្អាក់ការរៀនសូត្ររបស់កុមារ។ មណ្ឌលនេះលើកឡើងពីវឌ្ឍនភាពយឺតយ៉ាវនៃករណីផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងកុមារ ដែលបណ្តាលមកពីវិបត្តិកូវីដ-១៩ ពោលគឺក្នុង ៦៤ ករណីដែលបានដាក់ទៅតុលាការ មានតែ ៩ ករណីប៉ុណ្ណោះដែលកំពុងដំណើរការ។ ស្ថានភាពនេះបានអូសបន្លាយពេលក្នុងការស្តារឡើងវិញរហ័សសម្រាប់កុមារមួយចំនួន[២៥]។

## ៣.៥.២ មណ្ឌលសុវត្ថិភាព និងអ្នកផ្តល់សេវា ខ្វះធនធាន

កង្វះធនធានជាទូទៅ និងកង្វះបុគ្គលិកសង្គមកិច្ច ដែលទទួលការបណ្តុះបណ្តាល និងអ្នកចិត្តវិទ្យា សម្រាប់ថែទាំ និងជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាចំណុចទាល់ច្រកជារួមសម្រាប់ភាគីពាក់ព័ន្ធភាគច្រើននៅអាស៊ាន។ អ្នកផ្តល់សេវាអាចមិនទទួលបានការបណ្តុះបណ្តាលមូលដ្ឋានស្តីពីការធ្វើការជាមួយអ្នកដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត។ ការធានាភាពអាចរកបានបុគ្គលិកដែលមានគុណវុឌ្ឍិ និងការពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវា គឺជាកង្វល់ចម្បងសម្រាប់ភាគីពាក់ព័ន្ធ។ ការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាពសម្រាប់បុគ្គលិកមណ្ឌលសុវត្ថិភាព បុគ្គលិកសង្គមកិច្ច អ្នកប្រឹក្សាយោបល់ អ្នកគ្រប់គ្រងករណី និងអ្នកផ្តល់សេវាផ្សេងទៀត គឺជាតម្រូវការដ៏ចម្បង។ ទោះជាយ៉ាងណា ការណ៍នេះត្រូវបានរាំងស្ទះដោយកង្វះថវិកាសម្រាប់ទីភ្នាក់ងារពាក់ព័ន្ធ និងមណ្ឌលសុវត្ថិភាព ក្នុងការបំពេញអាណត្តិរបស់ខ្លួន។ នេះជាបញ្ហាមួយដែលរីកធំឡើងដោយសារវិបត្តិកូវីដ-១៩។

*យើងមានមណ្ឌលសុវត្ថិភាពតែ ២ ប៉ុណ្ណោះ មួយទៅទីក្រុងហាណូយ និងមួយទៀតនៅ Can Tho ដូច្នេះគឺមិនគ្រប់គ្រាន់នោះទេ។ យើងចង់ពង្រីកសេវារបស់យើង ឱ្យគ្របដណ្តប់លើប្រជាជនទាំងអស់ក្នុងប្រទេសវៀតណាម។*

*---(ផ្ទះសន្តិភាព សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសវៀតណាម ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២២)។*

*យើងមានតែមណ្ឌលសុវត្ថិភាពមួយដែលគ្រប់គ្រងដោយរដ្ឋ សម្រាប់ជនរងគ្រោះគ្រប់ប្រភេទ។ វាមិនងាយស្រួលនោះទេក្នុងការធ្វើប្រតិបត្តិការជាមណ្ឌលសុវត្ថិភាពមួយ ដោយផ្អែកលើថវិកា និងធនធានតិចតួចដែលយើងមាន។*

*---(សហជីពស្ត្រីឡាវ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឡាវ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២)។*

*ខ្ញុំនឿយណាយនឹងការនិយាយពីមណ្ឌលសុវត្ថិភាព។ ថវិកាត្រឹមតែ ១៦ ពាន់លានរូពីឥណ្ឌូនេស៊ីក្នុងមួយឆ្នាំ គឺមិនគ្រប់គ្រាន់នោះទេ ហើយយើងកំពុងទទួលករណីជួញដូរមនុស្សកាន់តែច្រើន។ យើងអាចផ្តល់កន្លែងស្នាក់នៅ និងអាហារដល់ពួកគេ ប៉ុន្តែយើងមិនអាចនិយាយពីគុណភាពបានទេ។ ថវិកាសម្រាប់ការផ្គត់ផ្គង់អាហារដល់កុមារម្នាក់ គឺបានត្រឹមតែ ២ សប្តាហ៍ប៉ុណ្ណោះ។ នេះជាឧបសគ្គរបស់យើង។*

*---(មជ្ឈមណ្ឌលផ្តល់សេវាចម្រុះសម្រាប់ការបង្កើនភាពអង់អាចរបស់ស្ត្រី និងកុមារ (P2TP2A) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២)។*

## ៣.៥.៣ ភាពខុសគ្នានៃគុណភាព និង សុវត្ថិភាពនៅតាមមណ្ឌលសុវត្ថិភាព

ភាពខុសគ្នានៃគុណភាព និងសុវត្ថិភាពនៅតាមមណ្ឌលសុវត្ថិភាពគឺជាការព្រួយបារម្ភមួយដែលលើកឡើងដោយភាគីពាក់ព័ន្ធមួយចំនួន។ ក្នុងមណ្ឌលសុវត្ថិភាពខ្លះមិនមានពិធីសារសន្តិសុខ មិនមានឆ្មាំយាមបរិវេណអគារឱ្យបានគ្រប់គ្រាន់ ឬក៏ទីតាំងមិនសូវមានសន្តិសុខ។ អ្វីដែលជាបញ្ហាគួបផ្សំគឺការភាន់ច្រលំចំពោះអ្នកដែលត្រូវទទួលខុសត្រូវលើការធានាសុវត្ថិភាពរបស់បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព (ប៉ូលីស ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ឬអ្នកគ្រប់គ្រងមណ្ឌលសុវត្ថិភាព)។

ភាគីពាក់ព័ន្ធមួយចំនួនលើកឡើងថា មានករណីបៀតបៀនផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញបុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។ ឧប្បត្តិហេតុទាំងនេះមិនសុទ្ធតែត្រូវបានរាយការណ៍ ឬចាត់ទុកជបញ្ហាដែលចាំបាច់ត្រូវដោះស្រាយនោះទេ។ ពួកគេបានលើកឡើងពីភាពចាំបាច់ក្នុងការរំលេចស្ថានភាពនេះ ដូចជា ការនាំយកបញ្ហានេះទៅបង្ហាញជូនព្រះរាជអាជ្ញា និងចៅក្រម ដើម្បីឱ្យជំរុញឱ្យពួកគេជួយពន្លឿនករណីដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ ដូច្នេះ មិនចាំបាច់អូសបន្លាយពេលដែលជនរងគ្រោះត្រូវស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពឡើយ។



### ៣.៥.៤ ការយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលមានតម្រូវការស្មុគស្មាញ

ការយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលមានវិបត្តិធ្ងន់ធ្ងរ ឬមានជំងឺផ្លូវចិត្ត គឺជាបញ្ហាប្រឈមចម្បងមួយសម្រាប់អ្នកអនុវត្តន៍។ភាគីពាក់ព័ន្ធលើកឡើងពី"ជនរងគ្រោះដែលស្រែកពេញមួយយប់" ដោយសារតែពួកគេមានទុក្ខផ្លូវចិត្ត។ កុមារតូចមួយចំនួនយល់សុបិន្តអាក្រក់ម្តងហើយម្តងទៀត និងដើរមមើ ដោយសារពួកគេធ្លាប់រងការប៉ះទង្គិចផ្លូវចិត្ត។ ដូច្នេះ មណ្ឌលសុវត្ថិភាពរងសម្ពាធក្នុងការចាត់តាំងបុគ្គលិកសង្គមកិច្ចឱ្យប្រចាំការ ២៤ ម៉ោង/៧ ថ្ងៃ។ ការធ្វើដូច្នេះ គឺមិនសុទ្ធតែអាចធ្វើទៅបានរហូតនោះទេ។

បញ្ហាប្រឈមមួយទៀត ពាក់ព័ន្ធនឹងការចាត់ចែងជនបរទេសដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ។ អ្នកផ្តល់មណ្ឌលសុវត្ថិភាពមិនអាចបញ្ជាក់ពីអាសយដ្ឋានរបស់ជនរងគ្រោះទាំងនេះ និងស្រាវជ្រាវរកគ្រួសាររបស់ពួកគេបានឡើយ។ ដូច្នេះ ជនរងគ្រោះមួយចំនួនត្រូវស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពរយៈពេលយូរ ហើយមានតិចតួចណាស់ដែលសង្ឃឹមថាអាចធ្វើមាតុភូមិនិវត្តន៍បាន។ ក្រៅពីនេះ អ្នកផ្តល់មណ្ឌលសុវត្ថិភាពត្រូវចរចាជាមួយមន្ត្រីអន្តោប្រវេសន៍ពាក់ព័ន្ធនឹងការនិរទេស ឬការដាក់ទោសព្រហ្មទណ្ឌជនរងគ្រោះជាជនបរទេស ដែលបានចូលមកក្នុងប្រទេសដោយខុសច្បាប់។

បច្ចុប្បន្ន យើងកំពុងជួយដល់ជនរងគ្រោះម្នាក់មកពីកោះកាលីម៉ាន់តាន់។ យើងមិនអាចធ្វើមាតុភូមិនិវត្តន៍គាត់បានទេ ព្រោះយើងមិនអាចផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់គាត់បាន។ គាត់មិនមានលេខអត្តសញ្ញាណប័ណ្ណព្រោះគាត់នៅជាអនីតិជននៅឡើយ។ យើងមិនអាចជួយដល់ការអប់រំរបស់គាត់បានទេ ព្រោះការិយាល័យអប់រំ Yogyakarta ផ្តល់ជំនួយការអប់រំសម្រាប់កុមារដែលជាពលរដ្ឋ Yogyakarta ប៉ុណ្ណោះ។ ដូច្នេះ យើងត្រូវទាក់ទងទៅសេវាសង្គមនៅកាលីម៉ាន់តាន់ ( Rifka Annisa ( NGO ) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២ )។



## ៣.៥.៥ កង្វះការសម្របសម្រួលរវាងទីភ្នាក់ងារនានា

ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្សជាដំណើរការស្មុគស្មាញដែលទាមទារការចូលរួមពីសំណាក់ក្រសួង ទីភ្នាក់ងារ និងអង្គការផ្សេងៗ ដូចជា ផ្នែកអនុវត្តន៍ច្បាប់ សង្គមកិច្ច ទីភ្នាក់ងារគាំពារសាក្សី សហជីពស្ត្រី អង្គការមិនមែនរដ្ឋាភិបាល និងអង្គការតាមសហគមន៍។ កង្វះទំនាក់ទំនង និងការសម្របសម្រួលរវាងអ្នកផ្តល់សេវាពាក់ព័ន្ធ អាចជះផលអវិជ្ជមានលើការស្តារឡើងវិញ និងការស្តារលទ្ធភាពពលកម្មរបស់ជនរងគ្រោះ។ ជនរងគ្រោះអាចរងគ្រោះជាថ្មី ប្រសិនបើពួកគេត្រូវបានសម្ភាសន៍ ឬសួរដដែលៗជាច្រើនដង ដោយអ្នកផ្តល់សេវាផ្សេងៗ។ ក្រៅពីនេះ ការពន្យារពេលដោយមិនចាំបាច់ក្នុងដំណើរការបញ្ជូន អាចកាត់បន្ថយទំនុកចិត្តរបស់ជនរងគ្រោះលើដំណើរការផ្តល់ជំនួយ ឬកាន់តែអាក្រក់ជាងនេះ រាំងស្ទះដល់សមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៍របស់ពួកគេ។

*មានភាពចាំបាច់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងាររវាងឆ្មាំព្រំដែន និងក្រសួងការងារ ទុព្វលជន និងសង្គមកិច្ច (MOLISA)។ ក្រៅពីនេះ យើងចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវការសង្គ្រោះ និងការបញ្ជូនជនរងគ្រោះរវាង MOLISA និងផ្ទះសន្តិភាព។ ខណៈដែលប្រទេសវៀតណាម មានកិច្ចសហការពហុទីភ្នាក់ងារដ៏ល្អ សហជីពស្ត្រីវៀតណាម មិនត្រូវបានលើកឡើងជាផ្លូវការក្នុងនីតិវិធីប្រតិបត្តិស្តង់ដារ ដែលចេញដោយ MOLISA ពាក់ព័ន្ធនឹងការសង្គ្រោះ និងការបញ្ជូនអ្នកដែលត្រូវបានជួញដូរឡើយ។*

*--(សហជីពស្ត្រីវៀតណាម សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅវៀតណាម ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២២)។*

*យើងព្យាយាមធ្វើឱ្យមានភាពបុរេសកម្ម ដើម្បីឱ្យយើងអាចផ្តល់ការគាំទ្រដល់ជនរងគ្រោះបានទាន់ពេលវេលា។ ឧ. ជំនួសឱ្យការរង់ចាំឯកសារផ្លូវការ យើងទាក់ទងទៅអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ឬថ្នាក់កណ្តាល និងស្នើសុំកិច្ចសហការរបស់ពួកគាត់។*

*---(ផ្ទះសន្តិភាព សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅវៀតណាម ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២២)។*

# ៣.៦ លើសពីមណ្ឌលសុវត្ថិភាពបិទជិត៖ ការបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងបង្កើនភាពអង់អាចសម្រាប់ទាំងអស់គ្នា

កិច្ចសន្ទនាស្តីពីសេរីភាពដើរហើរសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងនៅតែទាក់ទាញទស្សនៈយល់ឃើញផ្សេងៗ។ ការផ្តល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះ ទាមទារការរក្សាតុល្យភាពដោយប្រុងប្រយ័ត្ន ពោលគឺការថ្លឹងថ្លែងសិទ្ធិរបស់ជនរងគ្រោះ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធផ្សេងទៀត ដែលពេលខ្លះមានភាពចម្រូងចម្រាស់នឹងការនាំយកអ្នកជួញដូរមនុស្សទៅផ្តន្ទាទោស និងការគ្រប់គ្រងទេសន្តរប្រវេសន៍ដោយប្រសិទ្ធភាព។ តាមការលើកឡើងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ភាគីពាក់ព័ន្ធនៅអាស៊ាន (ទាំងវិស័យ រដ្ឋាភិបាល និងវិស័យមិនមែនរដ្ឋាភិបាល) មានការបកស្រាយផ្សេងៗគ្នាលើសេរីភាពដើរហើរសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអត្ថន័យរបស់វានៅក្នុងការអនុវត្ត។ វិបត្តិកូវីដ-១៩ បានរំលេចបញ្ហាមួយចំនួនដែលអ្នកផ្តល់មណ្ឌលសុវត្ថិភាពបានប្រឈមតាំងពីមុនវិបត្តិនេះ ដែលធ្វើឱ្យបញ្ហាទាំងនោះកាន់តែធ្ងន់ធ្ងរនៅចំពោះមុខនៃការខ្វះខាតថវិកា និងធនធាន។

នៅអាស៊ាន មានការឯកភាពគ្នាថ្មីមួយលើការឆ្ពោះទៅរកអភិក្រមផ្អែកលើសិទ្ធិ និងយកចិត្តទុកដាក់ចំពោះជនរងគ្រោះសម្រាប់ការផ្តល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ អ្នកអនុវត្តន៍ហាក់បានកំណត់ប៉ារ៉ាម៉ែត្រច្បាស់លាស់ និងបានបង្កើតគំនិតផ្តួចផ្តើមបែបច្នៃប្រឌិតដើម្បីលើកកម្ពស់បរិយាកាសដែលមានសុវត្ថិភាព និងបង្កើនភាពអង់អាចទាំងសម្រាប់បុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព និងបុគ្គលិក។ ទោះបីជាអ្នកផ្តល់មណ្ឌលសុវត្ថិភាព និងអ្នកឆ្លើយតបជួរមុខផ្សេងទៀតប្រឈមនឹងបញ្ហាយ៉ាងច្រើនក៏ដោយ ប៉ុន្តែនៅតែមានចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តលើការបង្កើត និងសាកល្បងអភិក្រមថ្មីៗសម្រាប់ការថែទាំជនរងគ្រោះ។ ខាងក្រោមនេះជាការអនុវត្តល្អមួយចំនួនដែលត្រូវបានលើកមកបង្ហាញក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ។

## *៣.៦.១ ការកសាងទំនុកចិត្ត និងភាពជឿជាក់*

ការកសាងទំនុកចិត្តជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាជំហានដំបូងដ៏សំខាន់មួយ និងជាគោលបំណងដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធទាំងអស់។ ចំណុចនេះត្រូវបានរំលេចក្នុងគំនិតផ្តួចផ្តើមប្រឆាំងអំពើជួញដូរមនុស្ស ដោយពិចារណាថា ជារឿយៗ បទពិសោធន៍ឆ្លងកាត់ការជួញដូរមនុស្សលេចឡើងជាមួយនឹងឧបាយកល និងអំពើក្បត់[២៦]។ ភាគីពាក់ព័ន្ធដែលចូលរួមយ៉ាងសកម្មក្នុងការថែទាំជនរងគ្រោះដោយផ្ទាល់ គូសបញ្ជាក់ថា ការផ្តល់ព័ត៌មានច្បាស់លាស់ និងសុក្រឹតដល់ជនរងគ្រោះ ជាធាតុផ្សំសំខាន់មួយនៃដំណើរការកសាងទំនុកចិត្តនេះ។ គួរយកចិត្តទុកដាក់លើរបៀបប្រព្រឹត្តចំពោះ និងនិយាយជាមួយជនរងគ្រោះ។



*ជនរងគ្រោះត្រូវការដឹងថា មណ្ឌលសុវត្ថិភាពរបស់យើងជាកន្លែងការពារ មិនមែនកន្លែងឃុំឃាំង ដើម្បីឱ្យពួកគេមានទំនុកចិត្តក្នុងការរស់នៅក្នុងមណ្ឌលសុវត្ថិភាពរបស់យើង។ យើងមិនអាចធានារយៈពេលនៃការស្នាក់នៅរបស់ពួកគេបានទេ ប៉ុន្តែយើងនឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ជនរងគ្រោះ ស្តីពីវឌ្ឍនភាពនៃករណីផ្លូវច្បាប់របស់ពួកគេ ដើម្បីបញ្ជាក់អះអាងដល់ពួកគេ។*

*---(MSDHS សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថៃ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២)។*

*យើងប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ភាសាផ្លូវការ និងផ្តល់ភាពកក់ក្តៅ នៅពេលនិយាយជាមួយជនរងគ្រោះ ដើម្បីលើកកម្ពស់បរិយាកាសដូចក្នុងគ្រួសាររបស់ពួកគេ។ អ្នកចំណូលថ្មីនឹងទទួលបានការតម្រង់ទិស ហើយនឹងមានការពិភាក្សាពីតម្រូវការរបស់ពួកគេដើម្បីធានាការផ្តល់ជំនួយដែលសមស្រប។ យើងគោរពការសម្រេចចិត្តរបស់ពួកគេ។*

*---(អង្គការ Village Foundation International (NGO) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅឡាវ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២)។*

*យើងសួរជនរងគ្រោះថាតើពួកគេព្រួយបារម្ភពីការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព ឬទេ។ ប្រសិនបើយើងកត់សម្គាល់ថា ជីវិត និងសុវត្ថិភាពរបស់ពួកគេរងការគំរាមកំហែង យើងនឹងត្រូវបង្ហាញព័ត៌មានដល់ពួកគេ។ យើងនឹងបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពរបស់យើង។ ប៉ុន្តែប្រសិនបើមិនមានករណីនេះទេ ពោលគឺប្រសិនបើពួកគេមិនរងការគំរាមកំហែង ប៉ុន្តែពួកគេចង់ស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពរបស់យើង យើងនៅតែអាចឱ្យពួកគេស្នាក់នៅបាន។*

*---(Rumah Faye (NGO) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២)។*

## *៣.៦.២ ការអនុវត្តអតិក្រមផ្អែកតាមករណី*

ភាគីពាក់ព័ន្ធនៅសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ បានកត់សម្គាល់កាលៈទេសៈដោយឡែកៗរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សម្នាក់ៗ ដោយអ្នកផ្តល់សេវាមានភាពបត់បែនខ្ពស់នៅពេលពិចារណាពីការរៀបចំមណ្ឌលសុវត្ថិភាពឱ្យបានល្អបំផុតសម្រាប់ជនរងគ្រោះម្នាក់ៗ។ នៅប្រទេសថៃ អ្នកផ្តល់មណ្ឌលសុវត្ថិភាពពិចារណាពីកត្តាជាច្រើន ដូចជា សាវតារសាសនា និងវប្បធម៌របស់ជនរងគ្រោះ តម្រូវការហិរញ្ញវត្ថុរបស់ជនរងគ្រោះ ជាពិសេសកាតព្វកិច្ចទ្រទ្រង់គ្រួសារ ប្រភេទជំនាញ និងចំណេះដឹងដែលជនរងគ្រោះចង់ទទួលបាន ។ល។ ដូច្នេះ អ្នកផ្តល់មណ្ឌលសុវត្ថិភាព ឬអ្នកគ្រប់គ្រងករណីមានកាតព្វកិច្ចរៀបចំផែនការអភិវឌ្ឍន៍សម្រាប់ជនរងគ្រោះម្នាក់ៗដើម្បីយល់ពីតម្រូវការជាក់លាក់របស់ពួកគេ និងរៀបចំផែនការជំនួយដែលមានប្រសិទ្ធភាពបំផុត។ ជនរងគ្រោះជាជនជាតិថៃដែលមិនចង់ស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅជួបជុំគ្រួសារវិញ ដោយអ្នកផ្តល់សេវាជាអ្នកទំនុកបម្រុងជនរងគ្រោះនៅផ្ទះរបស់ជនរងគ្រោះផ្ទាល់។

*ម៉ូដែលមណ្ឌលសុវត្ថិភាពរីកពាយរបស់ថៃអនុញ្ញាតឱ្យជនរងគ្រោះជាមនុស្សពេញវ័យចេញពីមណ្ឌលសុវត្ថិភាព និងស្វែងរកការងារ ក្រោមអំឡុងពេលស្តារឡើងវិញ ដើម្បីកុំឱ្យពួកគេមានអារម្មណ៍ថាជាប់ផុងនៅក្នុងមណ្ឌលសុវត្ថិភាព។ ជនរងគ្រោះមានសេរីភាពក្នុងការផ្តល់យោបល់ពីអ្វីដែលត្រូវចម្អិនក្នុងមួយសប្តាហ៍ ចម្អិនអាហារបែបស្រុកកំណើត សម្រេចចិត្តទទួលយកការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជ្រើសរើសពេលដែលត្រូវសម្រាក។ មណ្ឌលសុវត្ថិភាពគួរផ្តល់បរិយាកាសដូចនៅផ្ទះជនរងគ្រោះ។ យើងត្រូវស្តាប់ជនរងគ្រោះយ៉ាងយកចិត្តទុកដាក់។ ប្រសិនបើយើងយល់ថា ការសម្រេចចិត្ត និងបំណងប្រាថ្នារបស់ពួកគេអាចបង្កគ្រោះថ្នាក់ដល់ពួកគេ យើងត្រូវពន្យល់ដល់ពួកគេ*

*---(MSDHS សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសថៃ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២)។*

អង្គការមិនមែនរដ្ឋាភិបាលមួយនៅកម្ពុជា ព្យាយាមកែសម្រួលរយៈពេលស្នាក់នៅ និងកម្មវិធីជំនួយនៅមណ្ឌលសុវត្ថិភាពរបស់ខ្លួនទៅតាមតម្រូវការ និងស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ។ អង្គការនេះអនុវត្តម៉ូដែលផ្ទះអន្តរកាលដោយផ្តោតសំខាន់លើទំនាក់ទំនងដែលជួយព្យាបាលរបួស និងការដាក់បញ្ចូលការអភិវឌ្ឍអតិថិជនទៅក្នុងសកម្មភាពប្រចាំថ្ងៃ។ ជនរងគ្រោះអាចសម្រេចស្នាក់នៅរយៈពេលខ្លី ត្រឹមតែ ១-៣ សប្តាហ៍ ឬសម្រេចស្នាក់នៅរយៈពេលវែង ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬប្រឡូកក្នុងការងារ។ ការងារ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុគ្គលស្នាក់នៅរយៈពេលវែងនៅក្នុងមណ្ឌលមានរយៈពេល ៣-៦ ខែ និងតែងត្រូវបានផ្តល់ជូននៅក្រោមមណ្ឌលសុវត្ថិភាព តាមរយៈភាពជាដៃគូរបស់អង្គការមិនមែនរដ្ឋាភិបាលជាមួយនិយោជក និងកម្មវិធីបណ្តុះបណ្តាល។ ដោយកត់សម្គាល់ថា ការគាំទ្រ និងការគ្រប់គ្រងអតិថិជនគឺជាកិច្ចការដែលប្រើជំនាញខ្ពស់ ពួកគេបានជួលបុគ្គលិកមានគុណវុឌ្ឍិឱ្យទទួលខុសត្រូវលើការថែទាំជនរងគ្រោះដោយផ្ទាល់។ ពួកគេធានាថា បុគ្គលិកទាំងនេះស្ថិតក្រោមការត្រួតពិនិត្យបានល្អ ពាក់ព័ន្ធនឹងការត្រួតពិនិត្យគ្លីនិក/ការប្រជុំពិភាក្សាក្រោយពេលអនុវត្តសកម្មភាព (ទាំងផ្ទៃក្នុង និងខាងក្រៅ ជាបុគ្គល និងជាក្រុម) និងពាក់ព័ន្ធនឹងការត្រួតពិនិត្យការងារ ដើម្បីឱ្យមានការគ្រប់គ្រងបានល្អដែលធានាបរិយាកាសដូចនៅផ្ទះ។

ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលមួយនៅឡាវ បានអនុវត្តអភិក្រមផ្អែកតាមករណី នៅពេលផ្តល់មណ្ឌលសុវត្ថិភាព និងជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

*រយៈពេលនៃការស្នាក់នៅរបស់ជនរងគ្រោះ គឺមិនឋិតថេរនោះទេ៖ ពួកគេអាចស្នាក់នៅជាមួយពួកយើងក្នុងរយៈពេលខ្លី រយៈពេលមធ្យម ឬរយៈពេលវែង អាស្រ័យលើកាលៈទេសៈរបស់ពួកគេ និងនៅពេលមានការធានាសុវត្ថិភាពនៃការត្រឡប់ទៅជួបជុំគ្រួសារវិញ។ បុគ្គលិកសង្គមកិច្ចរបស់យើងនឹងតាមដានបន្តជាមួយពួកគេដើម្បីផ្តល់ការគាំទ្រសូម្បីតែនៅក្រោយពេលដែលពួកគេបានត្រឡប់ទៅផ្ទះវិញ។ គោលនយោបាយស្នូលរបស់យើងគឺភាពបត់បែនទៅតាមស្ថានភាពរបស់ជនរងគ្រោះ និងបទពិសោធន៍នៃការរងគ្រោះរបស់ពួកគេ*

*---(អង្គការ Village Focus International (NGO) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឡាវ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២)។*

នៅម៉ាឡេស៊ី ក្រសួងស្ត្រី គ្រួសារ និងអភិវឌ្ឍន៍សហគមន៍ (MWFCD) បានចាត់វិធានការឆ្ពោះទៅរកការលើកកម្ពស់សេរីភាពដើរហើររបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈអភិក្រម ២ មុខព្រួញ។ មណ្ឌលសុវត្ថិភាពត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យសុំការអនុញ្ញាតសិទ្ធិដើរហើរសេរី ជំនួសមុខឱ្យបុគ្គលស្នាក់នៅក្នុងមណ្ឌលឱ្យបានឆាប់រហ័ស ក្នុងអំឡុងពេលនៃការចេញដីកាការពារបណ្តោះអាសន្ន។ ដំណើរការផ្តល់ការអនុញ្ញាតនេះត្រូវបានពន្លឿនដោយអាជ្ញាធរពាក់ព័ន្ធ ដោយពិចារណាពីសារៈសំខាន់នៃការបង្កើនការការពារ និងការថែទាំជនរងគ្រោះនៅក្នុងប្រទេសម៉ាឡេស៊ី។ ការអនុញ្ញាតនេះក៏ត្រូវមានការវាយតម្លៃហានិភ័យគ្រប់ជ្រុងជ្រោយ ដែលរួមបញ្ចូលសន្តិសុខ សុខភាព និងចិត្តសាស្ត្រផងដែរ។ ទន្ទឹមនឹងនេះ មណ្ឌលសុវត្ថិភាពនីមួយៗមានឆន្ទានុសិទ្ធិក្នុងការសម្រេចពីវិធីល្អបំផុតដើម្បីអាចឱ្យជនរងគ្រោះដើរហើរដោយសេរី ដោយមិនប៉ះពាល់ដល់សុវត្ថិភាពរបស់ពួកគេ។ ជនរងគ្រោះភាគច្រើនចង់មានអ្នកអមដំណើរ នៅពេលចាកចេញពីមណ្ឌលសុវត្ថិភាព ព្រោះពួកគេយល់ថា ការធ្វើដូច្នេះគឺមានសុវត្ថិភាពជាង។ នេះជាការពិតសម្រាប់ជនរងគ្រោះជាជនបរទេសដែលមិនចុះសម្រុងនឹងការរស់នៅក្នុងប្រទេសផ្សេង ឬបរិយាកាសក្នុងប្រទេសនោះ។

## ៣.៦.៣ ការលើកកម្ពស់ការប្រើប្រាស់ការថែទាំតាមសហគមន៍

ការប្រើប្រាស់ការថែទាំតាមសហគមន៍ នៅក្រៅមណ្ឌលសុវត្ថិភាព ឬស្ថាប័នផ្លូវការ ត្រូវបានភាគីពាក់ព័ន្ធជាច្រើនទទួលស្គាល់ជាការអនុវត្តល្អ។ ការថែទាំតាមសហគមន៍ត្រូវបានចាត់ទុកជាអភិក្រមល្អប្រសើរមួយសម្រាប់ការលើកកម្ពស់ការស្តារឡើងវិញ និងការស្តារលទ្ធភាពពលកម្មរយៈពេលវែងរបស់ជនរងគ្រោះ។ ក្រៅពីនេះ ភាគីពាក់ព័ន្ធលើកឡើងពីការខិតខំធ្វើយ៉ាងណាឱ្យជនរងគ្រោះបានរស់នៅជួបជុំជាមួយគ្រួសារ ប្រសិនបើការធ្វើដូច្នេះ មានសុវត្ថិភាព និងប្រសិនបើគ្រួសារត្រៀមខ្លួនទទួលយក និងទំនុកបម្រុងពួកគេ។ នេះជាការពិតសម្រាប់កុមារដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

*ប្រសិនបើជនរងគ្រោះមិនចង់ស្ថិតក្រោមការការពារឃុំគ្រង និងស្នាក់នៅក្នុងមណ្ឌល យើងនឹងផ្តល់ជម្រើសដល់ពួកគេ។ ក្រៅពីនេះ យើងទទួលបានព័ត៌មានស្តីពីការវាយតម្លៃគ្រួសារ ឬសមត្ថភាពឪពុកម្តាយ នៅតាមមូលដ្ឋានពីមន្ត្រីសុខុមាលភាពសង្គម ដើម្បីពិនិត្យមើលការត្រៀមខ្លួនរបស់ជនរងគ្រោះក្នុងការត្រឡប់ទៅជួបជុំគ្រួសារ។ ក្នុងករណីនេះ សេវានឹងត្រូវបានផ្តល់ជូននៅក្នុងសហគមន៍របស់ពួកគេផ្ទាល់។*

*---(DSWD សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១)។*





*យើងត្រូវងាកទៅរកសេវាតាមសហគមន៍ ឬការថែទាំតាមគ្រួសារ។ ដំបូង ជនរងគ្រោះត្រូវបានថែទាំនៅក្នុងមណ្ឌលសុវត្ថិភាពរបស់យើង។ ជាទូទៅ យើងទាក់ទងទៅគ្រួសាររបស់ពួកគេ និងឱ្យពួកគេជួយដល់យើង។ យើងមិនចង់ឱ្យជនរងគ្រោះត្រូវបានរករឿងរំខានដោយសហគមន៍មូលដ្ឋាន នៅពេលពួកគេត្រឡប់ទៅគ្រួសារវិញនោះទេ។ យើងត្រូវពង្រឹងកម្លាំងចិត្ត ជីវិត និងឆន្ទៈរបស់ពួកគេ ដើម្បីឱ្យពួកគេអាចរស់នៅបន្តទៀតបាន។*

*---(ក្រសួងសង្គមកិច្ច សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២)។*

*ក្នុងករណីសមស្រប ការថែទាំក្នុងមណ្ឌលសុវត្ថិភាពគួរតែមានរយៈពេលខ្លី។ ក្នុងករណីដែលអតិថិជនចង់ស្នាក់នៅយូរដើម្បីទទួលការបណ្តុះបណ្តាវិជ្ជាជីវៈ ឬរកការងារធ្វើ យើងប្រើប្រាស់ដៃគូខាងក្រៅ និងពិចារណាពីលទ្ធភាពនៃការជួលបន្ទប់ដែលនៅជិតកន្លែងធ្វើការរបស់ពួកគេ ដើម្បីបញ្ចៀសការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពដោយមិនចាំបាច់។*

*---(Ratanak International សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសកម្ពុជា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២១)។*

## ៣.៦.៤ ការផ្ដោតលើការស្ដារឡើងវិញ និងសមាហរណកម្ម

ការផ្ដល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះ មិនមែនជាគោលដៅចុងក្រោយនោះទេ ប៉ុន្តែវាជាផ្នែកមួយនៃការផ្ដល់ការការពារ និងការថែទាំបន្តដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ភាគីពាក់ព័ន្ធបានគូសបញ្ជាក់ពីសារៈសំខាន់នៃការជួយដល់ការស្ដារឡើងវិញរបស់ជនរងគ្រោះ និងការត្រៀមខ្លួនពួកគេសម្រាប់ការធ្វើសមារណកម្មទៅក្នុងសង្គម។

*កម្មវិធីស្ដារឡើងវិញ និងស្ដារលទ្ធភាពពលកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស (RRPTP) ត្រូវបានសម្របសម្រួលតាមរយៈការគ្រប់គ្រងករណីចម្រុះដែលឆ្លើយតបនឹងយេនឌ័រ ពោលគឺបុគ្គលិកសង្គមកិច្ចដែលត្រូវបានចាត់តាំង វិភាគបញ្ហា និងតម្រូវការរបស់អ្នកដែលត្រូវបានជួញដូរ និងគ្រួសាររបស់ពួកគេ។ បុគ្គលិកសង្គមកិច្ចរបស់យើងកត់សម្គាល់ភាពលម្អៀងយេនឌ័រ និងប្រើប្រាស់ការថែទាំផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត ក្នុងការបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ពួកគេកំណត់រក និងវាយតម្លៃជម្លោះនៅក្នុងគ្រួសារ និងជួយឱ្យជនរងគ្រោះស្ដារទំនាក់ទំនងល្អជាមួយគ្រួសារ និងសហគមន៍។ ក្រោយសមាហរណកម្មដោយជោគជ័យ យើងសង្ឃឹមថា ជនរងគ្រោះនឹងបន្តទៅដំណាក់កាលទី ៣ នោះគឺភាពម្ចាស់ការដោយខ្លួនឯង។*

*---(DSWD សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១)។*

*ក្រោមច្បាប់ប្រឆាំងអំពើជួញដូរមនុស្សរបស់ថៃ យើងបានបង្កើតមូលនិធិប្រឆាំងអំពើជួញដូរមនុស្សដែលមានគោលបំណងផ្ដល់សំណងបង់ទានដល់ជនរងគ្រោះ ប៉ុន្តែអាចត្រូវបានប្រើប្រាស់សម្រាប់ទ្រទ្រង់ចំណាយប្រចាំថ្ងៃ ថ្លៃព្យាបាល ការបន្តការសិក្សា ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ឧ. ប្រសិនបើជនរងគ្រោះចង់ទទួលការបណ្ដុះបណ្ដាលឱ្យក្លាយជាអ្នកធុងកាហ្វេ និងលក់កាហ្វេ ធ្វើជាចុងភៅ និងសិក្សានៅសាលា Culinary Academy ពួកគេអាចស្នើសុំជំនួយហិរញ្ញវត្ថុ។ ជនរងគ្រោះជាច្រើនចង់រៀនភាសាអង់គ្លេស ដើម្បីអាចធ្វើការនៅបរទេសដោយស្របច្បាប់។ មូលនិធិនេះអាចផ្ដល់ប្រាក់ឧបត្ថម្ភមួយចំនួនសម្រាប់ឱ្យពួកគេចាប់ផ្ដើមជីវិតថ្មី។ ប្រាក់នេះគឺសម្រាប់ទាំងជនជាតិថៃ និងអ្នកមិនមែនជនជាតិថៃ និងមិនមានលក្ខខណ្ឌអ្វីឡើយ។ ប៉ុន្តែប្រសិនបើពួកគេមិនអាចទទួលបានមូលនិធិនេះទេ យើងអាចទៅកាន់អង្គការមិនមែនរដ្ឋាភិបាល និងដៃគូផ្សេងទៀត ដើម្បីស្នើសុំជំនួយ។*

*---(MSDHS សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសថៃ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២)។*

*បុគ្គលមួយចំនួនដែលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពមិនអាចស្វែងរកការងារខាងក្រៅបាន។ ដូច្នេះ អ្វីដែលយើងធ្វើគឺត្រូវបង្កើតតួនាទីនៅក្នុងមណ្ឌលសុវត្ថិភាពសម្រាប់ពួកគេ ដូចជា អ្នកដឹកនាំមណ្ឌលសុវត្ថិភាព ជំនួយការចុងភៅ អ្នកសម្របសម្រួលការងារបោកគក់ អ្នកចេញទៅទិញឥវ៉ាន់ ឬការឧទ្ទេសនាមបុគ្គលម្នាក់ផ្សេងទៀតដែលស្នាក់នៅក្នុងមណ្ឌល ដើម្បីចាត់តាំង។ យើងផ្ដល់ប្រាក់ឈ្នួលតិចតួចដល់ពួកគេដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុរបស់ពួកគេ។ បុគ្គលស្នាក់នៅក្នុងមណ្ឌលភាគច្រើនជាអ្នកទំនុកបម្រុងគ្រួសារតែម្នាក់ឯង ហើយពួកគេមានមនុស្សជាច្រើននៅផ្ទះដែលពឹងផ្អែកលើចំណូលពួកគេ។ ជាញឹកញាប់ យើងស្ដាប់លឺគ្រួសារដែលទូរស័ព្ទទៅពួកគេមិនសួរថា "តើអ្នកសុខសប្បាយជាទេ?" នោះទេ ប៉ុន្តែសួរថា "តើពេលណាអ្នកផ្ញើប្រាក់មកផ្ទះ"។*

*---(បទបង្ហាញដោយ HOME Singapore នៅសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១)។*



## ៣.៦.៥ ការលើកកម្ពស់អភិក្រមពហុវិស័យឆ្ពោះទៅរកការជួយដល់ជនរងគ្រោះ

ការអនុវត្តអភិក្រមពហុវិស័យ ធានាថា មានការសម្របសម្រួលល្អបំផុតរវាងទីភ្នាក់ងារផ្សេងៗ និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជាពិសេស ការគិតគូរពីតម្រូវការចម្រុះរបស់ជនរងគ្រោះ។ ក្នុងករណីមានការបង្កើតភាពជាដៃគូរឹងមាំ លទ្ធផលចុងក្រោយសម្រាប់អ្នកផ្តល់សេវា និងជនរងគ្រោះ ច្រើនតែមានភាពវិជ្ជមានបំផុត។

*យើងធ្វើការជាក្រុមពហុវិស័យ មិនត្រឹមតែក្នុងចំណោម VFI ក្រសួងការងារ និងសុខុមាលភាពសង្គម ឬក្រសួងអប់រំ និងកីឡាប៉ុណ្ណោះទេ ប៉ុន្តែយើងក៏សហការជាមួយសហជីពស្ត្រីឡាវនៅថ្នាក់ខេត្ត លើការប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ អង្គការដែលធ្វើការងារពាក់ព័ន្ធនឹងសុខភាព និងវេជ្ជសាស្ត្រជាដៃគូសំខាន់មួយទៀតរបស់យើង។ ក្រៅពីនេះ យើងបានសហការយ៉ាងស្អិតរមួតជាមួយមេធាវី និងប៉ូលីសប្រឆាំងការជួញដូរមនុស្សលើកិច្ចដំណើរការនីតិវិធីករណី ការស៊ើបអង្កេត ឬការតាមដានរកគ្រួសារ ។*

*---(Village Focus International (NGO) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឡាវ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២)។*

*យើងប្រាប់ជនរងគ្រោះអំពីអង្គការមិនមែនរដ្ឋាភិបាលដែលអាចជួយដល់ពួកគេក្នុងរយៈពេលវែង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលដែលអាចជួយដល់ជនរងគ្រោះ នៅពេលពួកគេត្រឡប់ទៅផ្ទះវិញ។ យើងចែករំលែកព័ត៌មានស្តីពីករណីរបស់ពួកគេជាមួយទីភ្នាក់ងារទទួលខុសត្រូវ ដើម្បីឱ្យទីភ្នាក់ងារទាំងនេះអាចត្រៀមខ្លួនជួយដល់ជនរងគ្រោះបាន។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមានជំនាញខាងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដូច្នេះ ពួកគេអាចជួយដល់ដំណើរការបណ្តឹង។ ជនរងគ្រោះជាអ្នកសម្រេចថាតើពួកគេចង់ចូលរួម និងអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល ធ្វើការជាមួយពួកគេ ឬទេ។*

*---(MSDHS សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសថៃ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២)។*

## ៣.៦.៦ ការសម្របទៅតាមវិបត្តិ និង ស្ថានភាពមនុស្សធម៌

វិបត្តិកូវីដ-១៩ បានបង្ខំឱ្យភាគីពាក់ព័ន្ធ (ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល) សម្របទៅតាមវិបត្តិដែលវិវត្តឥតឈប់ឈរ និងមានភាពច្នៃប្រឌិតក្នុងការថែទាំ និងការពារជនរងគ្រោះ។ កិច្ចសហការជិតស្និទ្ធក្នុងចំណោមទីភ្នាក់ងារពាក់ព័ន្ធ ហាក់ជាកត្តាចម្បងមួយសម្រាប់ភាពជោគជ័យនៃគំនិតផ្តួចផ្តើមមួយចំនួនក្នុងចំណោមគំនិតផ្តួចផ្តើមទាំងនេះ។

*ក្នុងអំឡុងវិបត្តិកូវីដ-១៩ យើងបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដើម្បីបញ្ជូនអតិថិជនដែលចង់ត្រឡប់ទៅសហគមន៍វិញ។ ការណ៍នេះបានផ្តល់ជម្រើសដល់អតិថិជន សូម្បីតែអ្នកដែលរស់នៅក្នុងតំបន់ដែលពិបាកចូលដល់ ដោយសារស្ថានភាពជំងឺកូវីដ-១៩ នៅពេលនោះ។ ក្រៅពីនេះ យើងបានបង្កើតផែនការប្រព្រឹត្តិកម្មដែលផ្អែកតាមតម្រូវការរបស់អតិថិជនម្នាក់ៗ ដើម្បីធានាការផ្តល់ជំនួយក្នុងទ្រង់ទ្រាយកាន់តែតូច ឬផ្អែកតាមអតិថិជនម្នាក់ៗ។ ចំណុចនេះគឺសំខាន់សម្រាប់សុខុមាលភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់អតិថិជន ព្រោះចល័តភាពរបស់ពួកគេត្រូវបានរឹតត្បិតដោយការបិទខ្ទប់ដែលរដ្ឋបានដាក់ចេញ និងការបិទកន្លែងធ្វើការ ឬកន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ពួកគេ។*

*---(Rattanak International សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសកម្ពុជា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២១)។*



*ក្នុងវិបត្តិកូវីដ-១៩ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត មានកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងមណ្ឌលចត្តាឡីស័ករដ្ឋនៅក្នុងខេត្ត ក្នុងការផ្ទេរជនទេសន្តរប្រវេសន៍ដែលបានត្រឡប់ពីប្រទេសថៃ ទៅមណ្ឌលចត្តាឡីស័ក។ គ្មានការកំណត់អត្តសញ្ញាណជនរងគ្រោះនៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែតនោះទេ ដោយសារវិបត្តិកូវីដ-១៩។ ការកំណត់អត្តសញ្ញាណជនរងគ្រោះធ្វើឡើងក្រោយពេលដែលពលករទេសន្តរប្រវេសន៍ទាំងនោះ ចាកចេញពីមណ្ឌលចត្តាឡីស័ក ក្រោយរយៈពេល ១៤ ថ្ងៃ និងនៅពេលដែលពួកគេទៅដល់សហគមន៍វិញ។ ជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និងការិយាល័យ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។*

*---(ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសកម្ពុជា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០២១)។*

*ក្នុងវិបត្តិកូវីដ-១៩ យើងសម្របទៅតាមស្ថានភាពយ៉ាងឆាប់រហ័ស និងបានផ្តល់ការណែនាំទៅតាមពិធីសារសុខភាព ផ្តោតអាទិភាពលើសេវាតាមអនឡាញ និងផ្តល់ការពិគ្រោះយោបល់ផ្ទាល់តែក្នុងស្ថានភាពបន្ទាន់ប៉ុណ្ណោះ។ ការរៀបចំមណ្ឌលសុវត្ថិភាព ប្រែប្រួលទៅតាមស្តង់ដារពិធីសារសុខភាព និងឯកសារពិសេសៗសម្រាប់សេវារបស់យើងក្នុងពេលមានជំងឺឆ្លងរាតត្បាត។*

*---(Rifka Annisa (NGO) សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២)។*

*ក្រសួងសង្គមកិច្ច បានរៀបចំផ្ទះការពារ Tanjung Pinang និងមជ្ឈមណ្ឌលព្យាបាលរបួស (RPTC), Bambu Apus RPTC និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មសង្គមចំនួន ៤១ សម្រាប់ការធ្វើមាតុភូមិនិវត្តពលករទេសន្តរប្រវេសន៍ឥណ្ឌូនេស៊ីដែលមានបញ្ហាចំនួន ៧.៣០០ នាក់ ចេញពីប្រទេសម៉ាឡេស៊ីនៅអំឡុងខែមិថុនា-កក្កដា ឆ្នាំ ២០២១។ ក្រៅពីការសម្របសម្រួលជាមួយក្រសួងការបរទេស ក្រសួងសង្គមកិច្ចបានធ្វើការជាមួយក្រុមការងារផ្សេងទៀត ដូចជា រដ្ឋាភិបាលថ្នាក់តំបន់ និងក្រុមការងារកូវីដ-១៩ ដើម្បីរៀបចំផែនការធ្វើមាតុភូមិនិវត្តពលករទេសន្តរប្រវេសន៍ឥណ្ឌូនេស៊ីតាមរយៈច្រកចូលនៅ Tanjuung Pinang និង Pontianak។*

*---(ក្រសួងសង្គមកិច្ច សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២)។*

*ក្នុងខែ មេសា ឆ្នាំ ២០២០ DSWD បានចេញសេចក្តីណែនាំ និងកំណត់សម្គាល់ដល់ប្រធានមជ្ឈមណ្ឌលទាំងអស់របស់យើងឱ្យចាត់វិធានការបង្ការ ក្នុងមណ្ឌលសុវត្ថិភាព DSWD និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថា មណ្ឌលសុវត្ថិភាពទាំងអស់ត្រៀមខ្លួនឆ្លើយតបនឹងករណីឆ្លងកូវីដ-១៩ និងការព្រួយបារម្ភផ្នែកសុខភាព។*

*---(DSWD សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅប្រទេសហ្វីលីពីន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១)។*

# ផ្នែកទី ៤៖
# អនុសាសន៍

ការផ្ដល់សេវាតាមមណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ជាដំណើរការដែលស្មុគស្មាញ និងលំបាក។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិបានលើកអនុសាសន៍ផ្សេងៗដើម្បីឆ្លើយតបនឹងកិច្ចពិភាក្សាស្ដីពីការផ្ដល់មណ្ឌលសុវត្ថិភាពក្នុងតំបន់អាស៊ាន។ ខណៈដែលអនុសាសន៍មួយចំនួន ដោះស្រាយបញ្ហាសេរីភាពដើរហើររបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយផ្ទាល់ អនុសាសន៍ផ្សេងទៀតដោះស្រាយបញ្ហាប្រឈមទូលំទូលាយពាក់ព័ន្ធនឹងការថែទាំ និងការការពារជនរងគ្រោះដែលមានពិពណ៌នាក្នុងឯកសារនេះ។ ACWC សូមផ្ដល់អនុសាសន៍ដូចខាងក្រោម នៅពេលផ្ដល់មណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ អនុសាសន៍មួយចំនួនដកស្រង់ចេញពីរបាយការណ៍ឆ្នាំ ២០១៨ របស់កម្មវិធី ASEAN-ACT។

***សម្រាប់អ្នកអនុវត្តន៍***

១. អនុវត្តអភិក្រម "មិនបង្កគ្រោះថ្នាក់" សម្រាប់ការផ្ដល់មណ្ឌលសុវត្ថិភាព និងជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស[២៧]។ ការណ៍នេះតម្រូវឱ្យអ្នកផ្ដល់សេវាធ្វើយ៉ាងណាកុំបង្កើតឡើងវិញនូវទិដ្ឋភាពពាក់ព័ន្ធនឹងបទពិសោធនដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ ប្រកាន់ខ្ជាប់ការអនុវត្តផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត និងបន្តគោរពតម្រូវការសុវត្ថិភាពផ្លូវចិត្ត។

២. លើកកម្ពស់ម៉ូដែលមណ្ឌលសុវត្ថិភាពដែលផ្អែកលើសិទ្ធិ និងយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដែលផ្ដោតលើតម្រូវការរបស់ជនរងគ្រោះ និងការផ្ដល់ការថែទាំ និងសេវាប្រកបដោយក្ដីមេត្តា និងការមិនវិនិច្ឆ័យ។ អភិក្រមនេះគាំទ្រឱ្យជនរងគ្រោះចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការ និងការសម្រេចចិត្តអំពីសុវត្ថិភាព ការស្ដារឡើងវិញ និងសមាហរណកម្មរបស់ពួកគេ។ អភិក្រមនេះទាមទារឱ្យអ្នកផ្ដល់សេវាជំរុញការចូលរួមរបស់ជនរងគ្រោះឱ្យបានទូលំទូលាយ និងដោយភាពស្មោះត្រង់ និងរៀបចំផែនការប្រព្រឹត្តិកម្មដែលផ្អែកតាមតម្រូវការជនរងគ្រោះម្នាក់ៗ។

៣. ធានាការផ្ដល់មណ្ឌលសុវត្ថិភាព និងសេវាផ្សេងទៀត តាមគោលការណ៍ស្ម័គ្រចិត្ត និងការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ។ ជនរងគ្រោះគួរយល់ច្បាស់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន មុននឹងចូលទៅក្នុងមណ្ឌលសុវត្ថិភាព។ បុគ្គលិកមណ្ឌលសុវត្ថិភាពគួរចំណាយពេលពន្យល់ពីវិធានក្នុងមណ្ឌលសុវត្ថិភាពដល់ជនរងគ្រោះ ដោយមានជំនួយពីអ្នកបកប្រែ ប្រសិនបើចាំបាច់ និងធានាថាជនរងគ្រោះមានអារម្មណ៍កក់ក្ដៅចំពោះវិធានទាំងនោះ។ គួរទទួលបានការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយជាប្រចាំ និងគួរអនុញ្ញាតឱ្យជនរងគ្រោះចាកចេញពីមណ្ឌលសុវត្ថិភាព ប្រសិនបើការធ្វើដូច្នោះមានសុវត្ថិភាព។



៤. សម្របសម្រួលឱកាសដែលមានសុវត្ថិភាព និងមានការរៀបចំត្រឹមត្រូវសម្រាប់ឱ្យជនរងគ្រោះភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារ ក្រោមការជ្រោមជ្រែងពីបុគ្គលិក។ ជនរងគ្រោះគួរមានសេរីភាពក្នុងការជួបគ្រួសារ និងមិត្តភក្តិ លើកលែងតែករណីដែលអាចប៉ះពាល់ដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ បុគ្គលផ្សេងទៀតដែលស្នាក់នៅក្នុងមណ្ឌល ឬបុគ្គលិកមណ្ឌលសុវត្ថិភាព។ បង្កើតទំនាក់ទំនងច្បាស់លាស់ និងស្មោះត្រង់ជាមួយគ្រួសារជនរងគ្រោះ ដូចជា ការគ្រប់គ្រងក្តីរំពឹងទុករបស់ពួកគេស្តីពីពេលដែលពួកគេអាចជួប ឬនិយាយជាមួយជនរងគ្រោះ។ ការណ៍នេះនឹងជួយឱ្យទទួលបានការយោគយល់ពីគ្រួសារជនរងគ្រោះនៅពេលដែលជនរងគ្រោះមិនយល់ថាពួកគេត្រៀមខ្លួនរួចរាល់ដើម្បីជួបគ្រួសារ។

៥. ធានាថា បរិវេណខាងមុខ និងខាងក្នុងមណ្ឌលសុវត្ថិភាព មិនមានលក្ខណៈដូចពន្ធនាគារ។ លើកកម្ពស់បរិយាកាសដែលផ្តល់ភាពកក់ក្តៅ និងភាពស្និទ្ធស្នាលនៅក្នុងមណ្ឌលសុវត្ថិភាព។ មណ្ឌលសុវត្ថិភាពគួរស្ថិតនៅក្នុងសហគមន៍ និងមិនគួរស្ថិតនៅទីតាំងដាច់ស្រយាល និងឆ្ងាយពីភាពស៊ីវិល័យ។ មណ្ឌលសុវត្ថិភាពមិនគួរមានស្លាកច្បាស់ពេក និងគួររក្សាជាសម្ងាត់នូវទីតាំងមណ្ឌលសុវត្ថិភាពដើម្បីការពារសុវត្ថិភាព និងឯកជនភាពរបស់បុគ្គលិក និងបុគ្គលស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។

៦. ដើម្បីជានាការផ្តល់ជំនួយដែលមានប្រសិទ្ធភាព និងសមស្រប វាជាការសំខាន់ដែលត្រូវពិចារណាពីតម្រូវការ និងការព្រួយបារម្ភជាក់លាក់របស់មនុស្សម្នាក់ៗ ចំណុចខ្លាំង និងធនធានផ្ទាល់ខ្លួន និងបំណងប្រាថ្នារបស់ជនរងគ្រោះ។ ឱ. ការបណ្តុះបណ្តាលវិជ្ជាជីវៈគួរបំពាក់បំប៉នជនរងគ្រោះនូវជំនាញចាំបាច់ ដើម្បីឱ្យពួកគេអាចរកបានការងារស្របច្បាប់ និងសមស្របបន្ទាប់ពីពួកគេចាកចេញពីមណ្ឌលសុវត្ថិភាព។ ចំណុចនេះមានន័យថា អ្នកផ្តល់សេវាគួរមានភាពបត់បែន និងត្រៀមខ្លួនបំពេញតម្រូវការ និងប្រឈមនឹងស្ថានភាពផ្សេងៗ តាមរយៈការបង្កើតប្រព័ន្ធបញ្ជូនធំទូលាយ និងការរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកផ្តល់សេវាផ្សេងទៀត ស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋាន និងវិស័យឯកជន។

៧. ធានាថា មណ្ឌលសុវត្ថិភាពទាំងអស់មានក្រមប្រតិបត្តិសម្រាប់បុគ្គលិក និងបុគ្គលស្នាក់នៅក្នុងមណ្ឌល ដែលយល់ដោយបុគ្គលិកមណ្ឌលសុវត្ថិភាព និងបុគ្គលស្នាក់នៅក្នុងមណ្ឌលទាំងអស់ មានការណែនាំជាក់លាក់ស្តីពីអ្វីដែលបុគ្គលិកគួរធ្វើ និងអ្នកដែលគួរជូនដំណឹងក្នុងករណីអាចមាន ឬមានការគំរាមកំហែងជាក់ស្តែងលើសន្តិសុខរបស់ជនរងគ្រោះ និង/ឬបុគ្គលិក ឬនៅពេលជនរងគ្រោះស្នើសុំ ឬបង្ហាញពីបំណងចង់ចាកចេញ។

៨. ពង្រឹងសមត្ថភាពរបស់បុគ្គលិកមណ្ឌលសុវត្ថិភាព ក្នុងការផ្តល់ព័ត៌មាន និងបង្កើនភាពអង់អាចរបស់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព ក្នុងការសម្រេចចិត្តពីការការពារ ជំនួយ ការស្តារឡើងវិញ និងសមាហរណកម្មសម្រាប់ខ្លួនឯង ជាពិសេសធានាថា បុគ្គលិកមិនបង្ខំឱ្យជនរងគ្រោះយល់ព្រមទទួលយកសេវា។

៩. បង្កើតយន្តការមួយដែលជនរងគ្រោះបន្តទទួលបានព័ត៌មានស្តីពីវឌ្ឍនភាព និងស្ថានភាពករណីរបស់ពួកគេ និងមានមធ្យោបាយសម្រាប់ស្នើសុំព័ត៌មានស្តីពីវឌ្ឍនភាព និងស្ថានភាពនោះបានគ្រប់ពេល។

១០. កំណត់រក និងលុបបំបាត់របាំងដែលរារាំងជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនឱ្យទទួលបានសេវាការពារ និងជំនួយ នៅក្រៅប្រព័ន្ធមណ្ឌលសុវត្ថិភាព សម្រាប់ជាមូលដ្ឋាននៃការអភិវឌ្ឍមណ្ឌលសុវត្ថិភាព ដែលកាន់តែបើកចំហរ និងម៉ូដែលនៃការផ្តល់ជំនួយ និងការការពារតាមសហគមន៍។

### *សម្រាប់អ្នកតាក់តែងគោលនយោបាយ*

១១. ធានាថា មណ្ឌលសុវត្ថិភាព និងការការពារ មិនពាក់ព័ន្ធនឹងឆន្ទៈរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ប្រសិនបើចំណុចនេះមានចែងច្បាស់ក្នុងច្បាប់ ឬគោលនយោបាយជាតិ ធានាធ្វើយ៉ាងណាបង្ហាញពីចំណុចនេះដល់ជនរងគ្រោះ មន្ត្រីអនុវត្តន៍ច្បាប់ និងអ្នកផ្តល់សេវា។ អ្វីដែលសំខាន់គឺមិនត្រូវសន្មតថា អ្នកអនុវត្តន៍ទាំងអស់មានចំណេះដឹងជ្រៅជ្រះស្តីពីច្បាប់ និងគោលនយោបាយឡើយ។

១២. ពិនិត្យមើលក្របខ័ណ្ឌគតិយុត្តស្តីពីការផ្តល់មណ្ឌលសុវត្ថិភាព ដើម្បីអាចឱ្យជនរងគ្រោះ-សាក្សីដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី រស់នៅក្រៅមណ្ឌលសុវត្ថិភាពដែលគ្រប់គ្រងដោយរដ្ឋ។ ប្រសិនបើពួកគេមិនអាចរស់នៅជាមួយគ្រួសារបាន គួរផ្តល់ជម្រើសផ្សេងសម្រាប់ការរស់នៅជាមួយនិយោជក ឬអង្គការតាមសហគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល។

១៣. លើកកម្ពស់អភិក្រមផ្អែកតាមករណី នៅពេលពិចារណាពីមណ្ឌលសុវត្ថិភាពល្អបំផុត និងការថែទាំ/ការការពារជនរងគ្រោះសម្រាប់បុគ្គលម្នាក់ៗ។ នេះជាការអនុវត្តល្អបំផុតដែលកំពុងត្រូវបានអនុវត្តក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន។ អភិក្រមនេះផ្តល់លទ្ធភាពឱ្យអ្នកតាក់តែងគោលនយោបាយ និងអ្នកផ្តល់សេវា រៀបចំអន្តរាគមន៍ដោយផ្អែកលើកាលៈទេសៈជាក់លាក់ និងផលប្រយោជន៍ល្អបំផុតរបស់ជនរងគ្រោះម្នាក់ៗ ទោះបីជាមានព្រំដែនកំណត់ក្នុងគោលនយោបាយ និងច្បាប់ជាធរមានក៏ដោយ។

១៤. ធានាថា ការជៀតជ្រែកសេរីភាពបំលាស់ទី ឬសិទ្ធិសេរីភាពដោយយោងតាមហេតុផលសន្តិសុខផ្អែកតាមការវាយតម្លៃហានិភ័យរបស់ជនរងគ្រោះដែលធ្វើឡើងដោយប៉ូលីស ក្រោមកិច្ចសហការជិតស្និទ្ធជាមួយជនរងគ្រោះ និងធានាថា ការរឹតត្បិតដែលបានដាក់ ជាលក្ខខណ្ឌតម្រូវអប្បបរមាដើម្បីកាត់បន្ថយការគំរាមកំហែងដែលអាចកើតឡើងចំពោះសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះ។

១៥. ធានថា សម្រាប់ជនរងគ្រោះដែលការវាយតម្លៃហានិភ័យបង្ហាញថា ត្រូវស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពបិទជិត ការវាយតម្លៃហានិភ័យត្រូវបានធ្វើឡើងជាបន្តបន្ទាប់ និងធ្វើបច្ចុប្បន្នភាពញឹកញាប់ ដើម្បីឆ្លើយតបនឹងស្ថានភាពរបស់ជនរងគ្រោះដែលវិវត្តឥតឈប់ឈរ ដើម្បីពិនិត្យមើលភាពចាំបាច់នៃការបន្តស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព។

១៦. បន្តអភិវឌ្ឍន៍ និងពង្រឹងជម្រើសសម្រាប់ឱ្យជនរងគ្រោះចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដោយមិនបន្តស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព ដូចជា តាមរយៈការផ្តល់សក្ខីកម្មជាមុន ការផ្តល់សក្ខីកម្មតាមវីដេអូ ឬដោយជនរងគ្រោះធ្វើមាតុភូមិនិវត្តដែលត្រឡប់មកផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ ដូចគ្នានេះដែរ គួរខិតខំអស់ពីលទ្ធភាពក្នុងការកាត់បន្ថយថិរវេលានៃកិច្ចដំណើរការនីតិវិធីសម្រាប់ករណីជួញដូរមនុស្ស ជាពិសេសក្នុងករណីមានការរឹតត្បិតចល័តភាពរបស់ជនរងគ្រោះ ដូចជា តាមរយៈការប្រើប្រាស់តុលាការពិសេស ចៅក្រម និងព្រះរាជអាជ្ញាដែលទទួលការបណ្តុះបណ្តាលពិសេស និងតាមរយៈការបញ្ជ្រាបការយល់ដឹងរបស់ចៅក្រម និងព្រះរាជអាជ្ញាស្តីពីផលអន្តរាយនៃការអូសបន្លាយពេលលើអ្នកដែលត្រូវបានជួញដូរ។

១៧. ចាត់ទុកការផ្តល់មណ្ឌលសុវត្ថិភាពមិនមែនជាមធ្យោបាយ ដើម្បីពន្លឿនគោលបំណងនៃយុត្តិធម៌ព្រហ្មទណ្ឌ ប៉ុន្តែជាផ្នែកមួយក្នុងខ្សែច្រវ៉ាក់នៃការស្តារឡើងវិញ ការស្តារលទ្ធភាពពលកម្ម និងសមាហរណកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ដូច្នេះ វាជាការសំខាន់ដែលត្រូវបង្កើត ឬកែលម្អស្តង់ដារអប្បបរមាសម្រាប់មណ្ឌលសុវត្ថិភាព (គ្រប់គ្រងដោយរដ្ឋ ឬមិនគ្រប់គ្រងដោយរដ្ឋ) ដោយអនុលោមតាមការយល់ដឹងជាអន្តរជាតិស្តីពីការស្តារឡើងវិញ និងសមាហរណកម្មសម្រាប់ជាមូលដ្ឋាននៃការរៀបចំលក្ខណៈវិនិច្ឆ័យផ្អែកតាមសិទ្ធិ ដើម្បីត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធមណ្ឌលសុវត្ថិភាព ដូចជា លក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធនឹងសេរីភាពដើរហើរ និងសិទ្ធិសេរីភាព។

១៨. អនុវត្តគោលការណ៍ដូចគ្នាមួយចំនួន ដែលត្រូវបានប្រើប្រាស់ក្នុងការចាត់ចែងផលប៉ះពាល់នៃវិបត្តិកូវីឌ-១៩ សម្រាប់វិបត្តិ ឬស្ថានភាពមនុស្សធម៌នាពេលអនាគតដែលអាចកើតឡើង។ គោលការណ៍រួមមាន៖ ផ្តោតលើអភិក្រមយកចិត្តទុកដាក់ចំពោះជនរងគ្រោះនៅក្នុងដំណើរការទាំងមូល បង្កើនកិច្ចសហការឆ្លងទីភ្នាក់ងារ/វិស័យ និងពហុកម្រិត ដើម្បីបន្តផ្តល់សេវា និងការគាំទ្រសំខាន់ៗ ធ្វើឱ្យបន្សុីគ្នានូវពិធីសារផ្ទៃក្នុងក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល និងអ្នកផ្តល់សេវា ដើម្បីកាត់បន្ថយជាអតិបរមានូវការភាន់ច្រលំ និងការរាំងស្ទះដល់ការជួយដល់ជនរងគ្រោះ និងទាញប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធ ឬបណ្តាញសេវាដែលមានស្រាប់ដើម្បីជួយដល់ក្រុមងាយរងគ្រោះដែលត្រូវការជំនួយសង្គ្រោះបន្ទាន់។



# ឯកសារយោង


ASEAN (2016). Gender Sensitive Guideline for Handling Women Victims of Trafficking in Persons. Jakarta: ASEAN Secretariat.

ASEAN (2023). ASEAN Do No Harm Guide for Frontline Responders: Safeguarding the Rights of Victims of Trafficking in Persons. Jakarta: ASEAN Secretariat.

Cordisco Tsai, L., Lim, V., Nhanh, C., & Namy, S. (2022). "They Did Not Pay Attention or Want to Listen When We Spoke": Women's Experiences in a Trafficking-Specific Shelter in Cambodia. Affilia, 37(1), 151–168.

Gallagher, A and McAdam, M (ND). 'Information Note on Freedom of movement for victims of trafficking'. ASEAN-Australia Counter Trafficking.

Gallagher, A and Pearson, E (2010) 'The High Cost of Freedom: A Legal and Policy Analysis of Shelter Detention for Victims of Trafficking', Human Rights Quarterly 32 (2010) 73-114.

McAdam, M (2018). Freedom of movement for persons identified as victims of human trafficking: An analysis of law, policy and practice in the ASEAN Region. ASEAN-Australia Counter Trafficking.

McAdam, M (2022) Implementation of the Non-Punishment Principle for Victims of Human Trafficking in ASEAN Member States, ASEAN-Australia Counter Trafficking.

Nordin, R. (2019). Protection of the Rights of the Victims of Human Trafficking: Has Malaysia Done Enough? Journal of Southeast Asian Human Rights, 300–316.

Surtees R (2013). After Trafficking: Experiences and Challenges in the (Re)Integration of Trafficked Persons in the Greater Mekong Sub-Region. Bangkok, Thailand: UNIAP/ NEXUS Institute.

# គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)

កិច្ចពិភាក្សា និងអនុសាសន៍របស់ ACWC ស្តីពីមណ្ឌលសុវត្ថិភាពនៅអាស៊ាន